

# ក្រមច្បាប់អនុវត្តន៍ការងាររបស់ MSC

“ យើងខ្ញុំខិតខំប្រឹងប្រែងប្រែជានាឲ្យបាន ថា និយោជិករបស់យើងទទួលបាននូវក្តីសង្ឃឹមលើកិច្ចការរយៈពេលវែងក្នុងលក្ខខណ្ឌការងារដែលប្រកបដោយសុវត្ថិភាព និងសុខភាព។ ”



រហូតមកដល់ពេលនេះ MSC បានក្លាយទៅជាក្រុមហ៊ុនដឹកជញ្ជូននាំមុខគេមួយតាមរយៈការផ្តល់នូវការយកចិត្តទុកដាក់ដ៏ប្រសើរចំពោះអតិជនរបស់យើងខ្ញុំនៅទូទាំងពិភពលោក។ ក្រុមហ៊ុនយើងខ្ញុំទទួលបានជំនឿទុកចិត្តតាមរយៈការរកស៊ីស្របច្បាប់ប្រកបដោយទំនួលខុសត្រូវ និងសុចរិតធម៌របស់យើងខ្ញុំ។

ក្រមច្បាប់អនុវត្តន៍ការងាររបស់ MSC បញ្ជាក់បន្ថែមនូវគោលការណ៍ដែល MSC ធ្វើអាជីវកម្ម។ ច្បាប់អនុវត្តន៍ការងារនេះប្រើចំពោះនិយោជិករបស់ MSC ទាំងអស់នៅការិយាល័យធំលើពិភពលោករបស់យើងខ្ញុំ ក៏ដូចជាទីភ្នាក់ងារលើពិភពលោករបស់យើងខ្ញុំទាំងអស់ដែរ។ វាកំណត់នូវបទដ្ឋានជារួមមួយសម្រាប់ប្រតិបត្តិការជារួមរបស់ MSC ទាំងអស់នៅគ្រប់ទីកន្លែងដែលក្រុមហ៊ុនយើងខ្ញុំធ្វើអាជីវកម្ម។

តាមរយៈការប្រើក្រមច្បាប់នេះនៅក្នុងកិច្ចការងារប្រចាំរបស់យើង ក្រុមហ៊ុន MSC នឹងរក្សាភាពពិតចំពោះគោលការណ៍អនុវត្តន៍ក្រមសិលធម៌ និងគុណតម្លៃរបស់យើងដែលជាស្នូលនៃអាជីវកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ។

សូមលោក/លោកស្រី ទទួលនូវការគោរពរាប់អានដ៏ស្មោះពីយើងខ្ញុំ។

**Diego Aponte**
*ប្រធានក្រុមហ៊ុន & អគ្គនាយក (CEO)*

តារាងមាតិកា

# ក្រមច្បាប់អនុវត្តន៍អាជីវកម្មរបស់ MSC


**4** **សន្ទានុក្រម**

**6** **សេចក្តីផ្តើម**

6 គុណតម្លៃជាស្នូលរបស់ MSC
7 ទិសដៅនៃក្រមច្បាប់
8 វិសាលភាពនៃក្រមច្បាប់
8 ការបកស្រាយក្រមច្បាប់
9 ការរាយការណ៍អំពីបញ្ហានៃការប្រព្រឹត្តខ្លាំផ្តង

**10** **បទដ្ឋានអនុវត្តន៍**

**11** **បរិស្ថាន**

**12** **សិទ្ធិមនុស្ស និងបទដ្ឋានប្រើប្រាស់កម្លាំងពលកម្ម**

12 ការមិនរើសអើង
13 ការគោរពគ្នាទៅវិញទៅមក និងការគោរពមនុស្សស្មើៗភាពគ្នា
13 ភាពចម្រុះ
13 ការយាយី និង
ការប្រព្រឹត្តបំពានផ្សេងៗទៀត
13 សេរីភាពចូលរួមសមាគមន៍
14 ពលកម្មដោយបង្ខំ និងទាសភាពនាសម័យទំនើប
14 ពលកម្មកុមារ និងកិច្ចការពារ កម្មករក្មេងៗ
14 សហគមន៍ និង ការចូលរួមរបស់ភាគីពាក់ព័ន្ធ
14 ការគាំទ្រសិទ្ធិមនុស្ស
15 សុខភាព និងសុវត្ថិភាពក្នុងអាជីព

**16** **ការប្រឆាំងបទស៊ីសំណូក**

**17** **ទំនាស់ផលប្រយោជន៍**

**18** **បទបញ្ញត្តិច្បាប់ស្តីពីការដាក់ទណ្ឌកម្ម**

**18** **ការលាងលុយកខ្វក់**

**19** **ច្បាប់ស្តីពីការប្រកួតប្រជែង**

**20** **កំណត់ត្រាអាជីវកម្ម និងហិរញ្ញវត្ថុ**

**20** **កិច្ចសន្យា**

**21** **ព័ត៌មានព័ត៌មានសម្ងាត់, កិច្ចការពារទិន្នន័យ និងសិទ្ធិឯកជន, និងឧបករណ៍អេឡិចត្រូនិក**

21 ព័ត៌មាន
21 កិច្ចការពារទិន្នន័យ និងសិទ្ធិឯកជន
21 ឧបករណ៍អេឡិចត្រូនិក

**22** **បណ្តាញសង្គម និងការនិយាយជាសាធារណៈ**

22 ការប្រើប្រាស់បណ្តាញសង្គមសម្រាប់ពាណិជ្ជកម្ម
22 ការនិយាយជាសាធារណៈ និងការចូលរួមក្នុងប្រព័ន្ធផ្សព្វផ្សាយ






# សទ្ទានុក្រម

នៅត្រង់ចំណុចដែលសមស្រប ពាក្យទាំងឡាយដែលជាឯកវចនៈ ត្រូវបញ្ចូលជាពហុវចនៈ និងត្រឡប់ទៅមក។ បើបរិបទមិនត្រូវការផ្សេងពីនេះទេ សេចក្តីយោងដល់បុំលិង្គត្រូវបញ្ចូលសេចក្តីយោងដល់ឥត្ថីលិង្គ។

**C**

### C-TPAT

មានន័យសំដៅដល់កម្មវិធីភាពជាដៃគូរវាងអង្គភាពគយ/ការពារព្រំដែន និងក្រុមហ៊ុនឯកជនដើម្បីប្រឆាំងភេរវកម្មដែលបង្កើតឡើងដោយស្ថាប័នគយ និងការពារព្រំដែន សរអ ដែលជាផ្នែកមួយនៃក្រសួងសន្តិសុខជាតិ សរអ។

**M**

### MSC

មានន័យសំដៅដល់ MSC ដែលបំព្រួញមកពីក្រុមហ៊ុន Mediterranean Shipping Company SA ដែលមានអាសយដ្ឋាននៅ 12-14 Chemin Rieu, 1208 Geneva, Switzerland។

**ក**

### ការចំណាយលើការសម្របសម្រួល

មានន័យសំដៅដល់ការចំណាយទូទាត់ ឬផលប្រយោជន៍ទាំងឡាយណាដែលមានការធ្វើឡើងដោយគោលបំណងនៃការចាត់ការឲ្យបានរហ័ស ឬការសម្របសម្រួលដល់ការបំពេញតួនាទីរបស់មន្ត្រីរដ្ឋាភិបាលលើចំណាត់ការជាធម្មតារបស់រដ្ឋមួយ។

### ការប្រព្រឹត្តឆ្គាំឆ្គង

មានន័យសំដៅដល់ការប្រព្រឹត្តខុសច្បាប់ ឬមិនត្រឹមត្រូវ ដែលបុគ្គលិកនិយោជិកម្នាក់បានធ្វើដែលមានជាអាទិ៍ ការរំលោភក្រមច្បាប់នេះ។

### ក្រមច្បាប់

មានន័យសំដៅដល់កំណែទម្រង់ចុងក្រោយបំផុតនៃឯកសារក្រមច្បាប់ប់អនុវត្តន៍ការងាររបស់ MSC ដែលបានបោះពុម្ពនៅលើWebsite.របស់ MSC។

## ជ

### ជំនូន/អំណោយ (ទាយជ្ជទាន)

មានន័យសំដៅដល់អ្វីមួយដែលមានតម្លៃក្នុងទំនាក់ទំនងការងារអាជីវកម្មរបស់ក្រុមហ៊ុន MSC និង *"បដិសណ្ឋារកិច្ចរបស់ក្រុមហ៊ុន"* មានន័យសំដៅដល់ព្រឹត្តិការណ៍/កម្មវិធីទាំងឡាយណាដែល MSC ឬទីភ្នាក់ងាររបស់ខ្លួនទទួលភ្ញៀវ ឬបុគ្គលិកនិយោជិតចូលរួមសម្រាប់គោលបំណងទាក់ទងនឹងការងារពាណិជ្ជកម្ម។ ឧទាហរណ៍សាមញ្ញៗមានជាអាទិ៍ អាហារមានតម្លៃសមស្រប, ព្រឹត្តិការណ៍/កម្មវិធីកីឡា, ការសម្ដែងល្ខោន និងព្រឹត្តិការណ៍/កម្មវិធីអប់រំសម្រាប់គោលបំណងទាក់ទងនឹងការងារពាណិជ្ជកម្ម។

## ទ

### ទីភ្នាក់ងារ(នានា)

មានន័យថា (i) ទីភ្នាក់ងារទូទាំងពិភពលោករបស់ MSC នៅពេលកំពុងដើរតួឲ្យ និងក្នុងនាមក្រុមហ៊ុន MSC និងរួមបញ្ចូល (គ្រប់ពេលដែលពាក់ព័ន្ធ) ទីភ្នាក់ងាររង(នានា)ដែលកំពុងដើរតួឲ្យ និងក្នុងនាមក្រុមហ៊ុន MSC, (ii) មណ្ឌលរៀបចំផែនការរបស់ MSC, (iii) ការិយាល័យសាខាក្រុមហ៊ុន MSC, (iv) ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ MSC, និង (v) បណ្ដាក្រុមហ៊ុនដែល MSC មានកិច្ចសន្យាព្រមព្រៀងគ្រប់គ្រងដឹកជញ្ជូនដែលកំពុងមានប្រសិទ្ធភាព: Mediterranean Shipping Company S.R.L. ដែលមាននៅទីតាំងនៅទីក្រុងសូរេនតូ (Sorrento) នៃប្រទេសអ៊ីតាលី និង MSC Shipmanagement limited ដែលមានទីតាំងនៅទីក្រុងលីម៉ាសូល (Limassol) នៃប្រទេសសៃប្រឹស (រួមដោយបញ្ចូលទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធ)។

### ទំនាស់ផលប្រយោជន៍

មានន័យសំដៅដល់ស្ថានភាពមួយដែលនិយោជិកកំពុងធ្វើការងារឲ្យ និង/ឬក្នុងនាមជា/ជួសមុខឲ្យក្រុមហ៊ុន MSC ទទួលបានផលប្រយោជន៍ឯកជនដែលអាចនឹងរំខានដល់ផលប្រយោជន៍របស់ MSC តាមរបៀបដែលនឹងបង្កើតឲ្យមានហានិភ័យមួយដែលការសម្រេចចិត្តគាត់អាចនឹងមានផលប៉ះពាល់ដោយផលប្រយោជន៍ឯកជន ឬផ្សេងពីនេះអាចនឹងធ្វើឲ្យខូចដល់ការបំពេញកាតព្វកិច្ចរបស់គាត់ជួសមុខឲ្យ/ក្នុងនាម MSC។

## ន

### និយោជិក

មានន័យសំដៅដល់បុគ្គលិកនិយោជិក, អ្នកតំណាង, មន្ត្រី, និងនាយកនានារបស់ MSC និងទីភ្នាក់ងាររបស់ខ្លួន។

## ប

### បណ្ដាញសង្គម

មានន័យសំដៅដល់ការប្រើWebsite និងកម្មវិធីជាឯកជន ឬផ្ទាល់ខ្លួនដើម្បីធ្វើទំនាក់ទំនងជាមួយអ្នកប្រើផ្សេងៗទៀត ឬដើម្បីរកមើលមនុស្សដែលមានចំណាប់អារម្មណ៍ស្រដៀងៗគ្នាទៅនឹងកម្មសិទ្ធិរបស់មនុស្សម្នាក់ដែលមានជាអាទិ៍ (តែមិនកំណត់ចំពោះ) Facebook និង LinkedIn។

### បណ្ដាញសង្គមរបស់ MSC

មានន័យសំដៅដល់បណ្ដាញសង្គម (Social Media) តែត្រង់ចំណុចបន្ថែមលើសពីនេះ បុគ្គលិកនិយោជិកម្នាក់បង្ហើបឲ្យដឹងអំពីឋានៈក្នុងការងារនៅ MSC របស់បុគ្គលិកនិយោជិក(ដោយផ្ទាល់) ដែលមានដូចជា ធ្វើការនិយាយអះអាង ឬធានាដល់MSC (ឬដោយប្រយោល) ដែលមានដូចជា បង្ហោះរូបថតបង្ហាញអត្តសញ្ញាណ MSC ឧទាហរណ៍ ដោយមានឡូហ្គោ MSC នៅផ្ទៃខាងក្រោយ។

### បទទទួលសំណូក

មានន័យសំដៅដល់សកម្មភាព ឬការប្រព្រឹត្តបុគ្គលិកនិយោជិកម្នាក់ (ដោយផ្ទាល់ ឬប្រយោល) ដើម្បីរំអង្គាស, យល់ព្រមទទួលយក, ឬទទួលបាននូវផលប្រយោជន៍ច្រើនលើសលប់មួយសម្រាប់អត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់រូបគេ ឬសម្រាប់អត្ថប្រយោជន៍នៃបុគ្គលទីបីសម្រាប់ការទទួលបានកម្រៃជើងសា ឬការបំភ្លេចចោល/ខកខានប្រព្រឹត្តនូវទង្វើមួយដែលមានទំនាក់ទំនងទៅនឹងសកម្មភាពអាជីព ឬពាណិជ្ជកម្មរបស់ខ្លួនដែលផ្ទុយទៅនឹងកាតព្វកិច្ច ឬចំណុះគេតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

### បទផ្ដល់សំណូក

មានន័យសំដៅដល់សកម្មភាព ឬការប្រព្រឹត្តទាំងឡាយណាដែល (ដោយផ្ទាល់ ឬប្រយោល) ស្នើផ្ដល់ឲ្យ, សន្យា ឬផ្ដល់ទៅឲ្យបុគ្គលណាម្នាក់នៃផ្នែកឯកជននូវផលប្រយោជន៍ហួសហេតុមួយ ប្រយោជន៍បណ្ដាលឲ្យបុគ្គលនោះចូលរួម ឬខកខានប្រព្រឹត្តនូវទង្វើមួយដែលមានទំនាក់ទំនងទៅនឹងសកម្មភាពអាជីព ឬពាណិជ្ជកម្មរបស់ខ្លួនដែលផ្ទុយទៅនឹងកាតព្វកិច្ច ឬចំណុះគេតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

## ព

### ព័ត៌មានផ្ទាល់ខ្លួន

មានន័យសំដៅដល់ព័ត៌មាន ឬទិន្នន័យទាំងឡាយណាដែលទាក់ទងនឹងបុគ្គលធម្មតាដែលស្គាល់ ឬអាចកំណត់អត្តសញ្ញាណបាន។ ព័ត៌មានផ្ទាល់ខ្លួនគឺជាចំណុចនីមួយៗនៃទិន្នន័យដែលទាក់ទងនឹងបុគ្គលមួយប្រភេទ ដោយមិនគិតដល់ទម្រង់ដែលវាមានការបង្ហាញប្រាប់ និងទ្រង់ទ្រាយឯកសារព័ត៌មាន (មធ្យោបាយរក្សាទុកទិន្នន័យ, ក្រដាស, ខ្សែអាត់, ភាពយន្ត, មធ្យោបាយប្រើប្រព័ន្ធអេឡិចត្រូនិក ជាដើម)។ សម្រាប់គោលបំណងនៃគោលនយោបាយ (ផែនការ) នេះ មិនត្រូវមានការផាត់ចេញនូវនីតិបុគ្គលនានាចេញពីវិសាលភាពរបស់ខ្លួនទេ បើផ្សេងពីនេះមិនមានការចែងក្នុងច្បាប់ការពារទិន្នន័យក្នុងឧបករណ៍។ ព័ត៌មានផ្ទាល់ខ្លួនក្ដោបលើព័ត៌មានដែលទាក់ទងទៅនឹងបុគ្គលដែលអាចកំណត់អត្តសញ្ញាណបាន។ មានវិធីខុសៗគ្នាដែលគេអាចចាត់ទុកបុគ្គលម្នាក់ថា៖ 'អាចកំណត់អត្តសញ្ញាណបាន'។ ឈ្មោះពេញរបស់បុគ្គលម្នាក់គឺជាអង្គសំគាល់ដោយផ្ទាល់មួយ។ លើសពីនេះ សមាយោគនៃព័ត៌មានផ្សេងៗទៀត អាចនឹងមានលក្ខណៈគ្រប់គ្រាន់ដើម្បីកំណត់អត្តសញ្ញាណបុគ្គលម្នាក់បាន។ ព័ត៌មានផ្ទាល់ខ្លួនអាចទាក់ទងគួរឲ្យកត់សំគាល់ (តែមិនកំណត់ចំពោះ) លើឈ្មោះ, ថ្ងៃខែឆ្នាំកំណើត, អាសយដ្ឋាន; អាសយដ្ឋានអ៊ីម៉ែល និងលេខទូរសព្ទផ្ទាល់ខ្លួន និងក្នុងអាជីព (ដោយមិនគិតដល់ករណីដែលគេប្រើវាសម្រាប់គោលបំណងផ្ទាល់ខ្លួន និងក្នុងអាជីព); បរិយាយមុខទំនិញពាក់ព័ន្ធនឹងឈ្មោះ ឬព័ត៌មានលម្អិតនៃមនុស្សទំនាក់ទំនងរបស់ភាគីនានានៅក្នុងកិច្ចសន្យានៃការដឹកនាំ; មូលដ្ឋានីយកម្មភូមិសាស្ត្រនៃកុងតឺន័ររបស់អតិថិជន; ព័ត៌មានលម្អិតអំពីវិជ្ជាជីវៈរបស់និយោជិក, ឋានៈការងារ, លេខផ្លាកសញ្ញា; ព័ត៌មានលម្អិតនៃមនុស្សទំនាក់ទំនងជាអតិថិជន ឬព័ត៌មានលម្អិតផ្នែកហិរញ្ញវត្ថុរបស់អតិថិជន ឬព័ត៌មានមួយចំនួនផ្សេងទៀតដែលចាំបាច់ត្រូវមានសម្រាប់ការពិនិត្យមើលរបាយការណ៍ឥណទាន; អាសយដ្ឋានអាយភី (IP) ឬលេខស៊េរីនៃឧបករណ៍មួយ។

### ព័ត៌មានសម្ងាត់

មានន័យសំដៅដល់ព័ត៌មាននៅក្នុងការកាន់កាប់ទាក់ទងទៅនឹងអាជីវកម្មរបស់ក្រុមហ៊ុន MSC ទីភ្នាក់ងារនានារបស់ខ្លួនដែលមិនត្រូវផ្សព្វផ្សាយជាសាធារណៈ (មានជាអាទិ៍ (តែមិនកំណត់ចំពោះ) កិច្ចសន្យា, ព័ត៌មានកំណត់ថ្លៃ, ផែនការទីផ្សារ, ទំហំពាណិជ្ជកម្ម, អត្តសញ្ញាណអតិថិជន, ប្រតិបត្តិការ និងលម្អិតផ្នែកបច្ចេកទេសនៃកប៉ាល់, ការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមួយចំនួនផ្សេទៀតអំពីតម្លៃពាណិជ្ជកម្ម) ដល់មនុស្សមួយចំនួនផ្សេងទៀតដែលមានការប្រាស្រ័យទាក់ទងប្រាប់គ្នាតាមមធ្យោបាយណាមួយ (មានជាអាទិ៍ មធ្យោបាយផ្សាយប្រាប់ផ្ទាល់មាត់ និង/ឬតាមប្រព័ន្ធអេឡិចត្រូនិក បើទោះជាមានការកត់សំគាល់ ឬគ្មានក៏ដោយ) ដែលកំណត់ទុកជាមុន ឬដែលផ្សេងពីនេះមានការកំណត់ប្រភេទថាជាព័ត៌មាន "សម្ងាត់"។

## ម

### មន្ត្រីរដ្ឋាភិបាល

មានន័យសំដៅបុគ្គលម្នាក់ដែល: (i) កំពុងបម្រើការងារឲ្យ, ទទួលបានការងារពី ឬកំពុងដើរតួជាភ្នាក់ងារម្នាក់នៃទីភ្នាក់ ឬអង្គភាពរដ្ឋាភិបាលថ្នាក់ជាតិ, រដ្ឋ ឬក្រុងរបស់ប្រទេសណាមួយ; (ii) កំពុងបម្រើការឲ្យ, ទទួលបានការងារពី ឬកំពុងដើរតួជាភ្នាក់ងារម្នាក់នៃអង្គការអន្តរជាតិ ជាសាធារណៈណាមួយ (ដូចជា ធនធនាគាពិភពលោក ឬអង្គការសហប្រជាជាតិ); (iii) កំពុងធ្វើការក្នុងសហគ្រាសពាណិជ្ជកម្មដែលគ្រប់គ្រង ឬត្រួតត្រាដោយរដ្ឋាភិបាលណាមួយ; (iv) កំពុងធ្វើការងារក្នុងបក្សនយោបាយមួយ។

## ឧ

### ឧបករណ៍អេឡិចត្រូនិក(នានា)

មានន័យសំដៅដល់គ្រឿងបរិក្ខារអេឡិចត្រូនិកណាមួយដែលគេប្រើជាសំខាន់សម្រាប់ការប្រាស្រ័យទាក់ទងគ្នា, ដំណើរការ និងការផ្ទេរព័ត៌មាន (ដែលមានជាអាទិ៍ ព័ត៌មានសម្ងាត់ និងផ្ទាល់ខ្លួន) នៅកន្លែងជំនាញ។ ឧបករណ៍ប្រភេទអស់ទាំងនេះមានជាអាទិ៍ (តែមិនកំណត់ចំពោះ) ម៉ាស៊ីនកុំព្យូទ័រយួរដៃ, ម៉ាស៊ីនកុំព្យូទ័រប្រើលើតុ, ម៉ាស៊ីនបម្រើ (សឺវើ), ទូរសព្ទដៃ, ថេប្លេត, ស៊ីមកាដនៃឧបករណ៍ចល័ត, ឧបករណ៍ផ្ទុកទិន្នន័យស្ដាទិក ឬដោះបានក៏ដូចជាសហ្វវែរដែលបានបញ្ចូល ឬរក្សាទុកក្នុងឧបករណ៍ប្រភេទអស់ទាំងនេះ។

## អ

### អ្នកអនុវត្តក្រមច្បាប់

មានន័យសំដៅដល់បុគ្គលដែលទទួលខុសត្រូវលើការមើលខុសត្រូវចំពោះការអនុវត្តក្រមច្បាប់អនុវត្តន៍ការងាររបស់ MSC នៅក្នុងទីភ្នាក់ងារមួយ។

### អំពើពុករលួយ

មានន័យសំដៅដល់ទង្វើនៃការផ្ដល់, ការសន្យា ឬការផ្ដល់ឲ្យមន្ត្រីរដ្ឋាភិបាលម្នាក់ (ដោយផ្ទាល់ ឬប្រយោល) នូវផលប្រយោជន៍ច្រើនហួសហេតុមួយ ប្រយោជន៍បណ្ដាលឲ្យបុគ្គលនោះចូលរួម ឬខកខានប្រព្រឹត្តនូវទង្វើមួយដែលមានទំនាក់ទំនងទៅនឹងសកម្មភាពអាជីព ឬពាណិជ្ជកម្មរបស់ខ្លួនដែលផ្ទុយទៅនឹងកាតព្វកិច្ច ឬចំណុះគេតាមឆន្ទានុសិទ្ធិរបស់ខ្លួន។



# សេចក្តីផ្តើម

## គុណតម្លៃជាស្នូលរបស់ MSC

គុណតម្លៃជាស្នូលនានារបស់ MSC បង្កើតបានជាមូលដ្ឋានគ្រឹះរបស់ក្រុមហ៊ុននេះ។ គុណតម្លៃទាំងនេះទ្រទ្រង់នូវទស្សនៈរបស់ MSC, បង្កើតនូវទម្រង់វប្បធម៌របស់ MSC និងបង្កើតឲ្យមាននូវទិសដៅនាពេលអនាគតរបស់ក្រុមហ៊ុន MSC នេះ។ គុណតម្លៃទាំងនេះ ក៏ដឹកនាំការអនុវត្តការងារជាទូទៅរបស់បុគ្គលិកនិយោជិកទាំងអស់នៅក្នុងបញ្ហាទំនាក់ទំនងគ្នាទៅវិញទៅមករបស់ពួកគេ។

### យើងគឺជា **ក្រុមហ៊ុន មានលក្ខណៈជាគ្រួសារមួយ**

ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនដែលមានគ្រួសារជាស្ថាបនិកនេះ ញ៉ាំងឲ្យយើងមាន ការបរិច្ចាកជូនសាធារណៈ និងការជឿទុកចិត្ត, ការបង្កើននូវតម្រូវការដ៏សំខាន់បំផុតរបស់មនុស្ស។
ការរួមស្មារតីទាក់ទងនឹងសហគ្រាសរបស់គ្រួសារនេះ ដឹកនាំយើងឲ្យដើរតួនាទីសំខាន់ជាមុន, យ៉ាងក្លាហាន និងប្រកបដោយការទទួលខុសត្រូវលើចំណាប់អារម្មណ៍ដ៏ល្អបំផុតរបស់អតិថិជន និងក្រុមហ៊ុនយើងខ្ញុំ។

### យើងមាន **សេចក្តីប្រឹងប្រែង**

យើងមានការប្រឹងប្រែង ឬក្លៀវក្លាលើអ្វីដែលយើងធ្វើ គឺយើងប្រឹងមានៈខ្លួនឯងដើម្បីសម្រេចបាននូវឧត្តមភាព ហើយយើងមានលក្ខណៈស្វិតស្វាយនៅក្នុងការជម្នះឧបសគ្គនានា។
ដោយសហការគ្នាប្រកបដោយសេចក្តីក្លៀវក្លា និងសេចក្តីសាទរ យើងផ្តល់បាននូវបទពិសោធន៍ដ៏វិសេសវិសាលមួយជូនដល់អតិថិជនរបស់យើង។

### យើងកំពុងស្ថិតនៅក្នុង **ការលូតលាស់ ជាបន្តបន្ទាប់**

ប្រពៃណី, ជំនាញ, វិជ្ជាជីវៈនិយម និងមហច្ឆតារបស់យើង ជំរុញឲ្យមានការរីកចម្រើនយ៉ាងលឿន និងប្រកបដោយនិរន្តរភាពរបស់ក្រុមហ៊ុននេះ។
យើងខិតខំស្វះស្វែងរកដំណោះស្រាយថ្មីៗបំផុតដើម្បីចាប់ក្រសោបយកការផ្លាស់ដែលជានិច្ចកាលគោរពដល់កិច្ចការពារសុវត្ថិភាព និងបរិស្ថាន។

### យើង **យកចិត្តទុកដាក់ចំពោះ មនុស្ស**

យើងជឿជាក់ថា មនុស្សម្នាក់នាំមកនូវគុណតម្លៃពិសេសដាច់ដោយឡែកៗពីគ្នា។
យើងបង្កើតទំនាក់ទំនងពិតប្រាកដដែលកសាងឡើងដោយអាស្រ័យលើក្រមសីលធម៌, ការគោរពសិទ្ធិគ្នា និងស្មារតីក្រុមការងារ។
យើងពិតជាយកចិត្តទុកលើសេចក្តីពេញចិត្ត និងភក្តីភាពរបស់អតិថិជន និងបុគ្គលិកនិយោជិករបស់យើង។

### យើងជឿជាក់លើ **ឱកាស ស្មើៗភាពគ្នា**

បេសកកម្មរបស់យើង គឺដើម្បីផ្តល់មនុស្សរបស់យើងនូវការបំពេញបំណងផ្ទាល់ខ្លួន និងភាពបរិបូណ៌។
យើងមានការប្តេជ្ញាចិត្តចំពោះការចែករំលែកចំណេះដឹងរបស់យើង ការផ្តល់នូវការបណ្តុះបណ្តាល និងជំនួយដែលបង្កលទ្ធភាពឲ្យមានការរីកចម្រើនវិជ្ជាជីវៈនៃមនុស្សរបស់យើង។
យើងធានាបាននូវឱកាសស្មើៗគ្នាដែលផ្តល់ ការអភិវឌ្ឍការងារអាជីពរយៈពេលវែង, ដែលក្រសោបយកពហុភាព និងដែលវាយតម្លៃខ្ពស់ចំពោះវប្បធម៌ទាំងអស់។

## ទិសដៅនៃក្រមច្បាប់

ក្នុងនាមជាក្រុមហ៊ុនដឹកជញ្ជូននាំមុខគេលើពិភពលោកមួយ MSC ទទួលបាននូវកេរ្តិ៍ឈ្មោះ និងជំនឿទុកចិត្តរបស់ខ្លួន ជារៀងរាល់ថ្ងៃតាមរយៈការផ្ដល់សេវាកម្មដ៏វិសេសវិសាវិសេសវិសាល លើសគេជូនដល់អតិថិជនរបស់ខ្លួន និងតាមរយៈការរកស៊ីយ៉ាងត្រឹមត្រូវ និងប្រកបដោយការគោរពក្រមសីលធម៌។ កេរ្តិ៍ឈ្មោះសម្រាប់ការជឿទុកចិត្ត និងសុចរិតភាពរបស់យើង អាស្រ័យលើរាល់សកម្មភាពប្រចាំថ្ងៃរបស់និយោជិកគ្រប់ៗរូប។

ក្រមច្បាប់នេះមានលក្ខណៈបំពេញបន្ថែមលើ និងត្រូវតែមានការអានឲ្យជួនគ្នាជាមួយនឹងគោលនយោបាយ និងទម្រង់ការផ្សេងៗទៀតដែលក្រុមហ៊ុន MSC អាចនឹងអនុម័តយកសម្រាប់គោលបំណងអនុវត្តន៍គោលការណ៍នៃច្បាប់នេះក្រមច្បាប់នេះ ក៏ដូចជាគោលនយោបាយ (ផែនការ) ផ្សេងៗទៀតដែរ។

លើសពីនេះ MSC សូមរក្សាសិទ្ធិកែប្រែក្រមច្បាប់នេះជានិច្ច។ និយោជិកត្រូវបន្តជ្រាប និងដឹងអំពីព័ត៌មានបច្ចុប្បន្នភាពមួយចំនួន។ គេអាចរកមើលសំណៅកំណែថ្មីបំផុតនៃក្រមច្បាប់នេះនៅលើវិបសាយរបស់ក្រុមហ៊ុន MSC បាន។

និយោជិកមានសិទ្ធិលើកយកមកចោទសួរនូវសំណួរណាមួយអំពីក្រមច្បាប់ និងការប្រតិបត្តិតាមរបស់វាតាមរយៈអ៊ីម៉ែលដែលមានអាសយដ្ឋាន ethic@msc.com។



## វិសាលភាពនៃក្រមច្បាប់

ក្រមច្បាប់នេះគឺជាគោលការណ៍ណែនាំមួយដែលនឹងជួយនិយោជិកនិងទីភ្នាក់ងារនានាដំណើរការការងារ អាជីវកម្មបានប្រកបដោយក្រមសីលធម៌។ ការអនុវត្តតាមក្រមច្បាប់នេះ គឺមានអាទិភាពខ្ពស់បំផុតសម្រាប់ក្រុមហ៊ុន MSC ហើយ MSC រំពឹងថា បណ្តាទីភ្នាក់ងារ និងនិយោជិកទាំងអស់នឹងប្រកាន់យកវាយ៉ាងខ្ជាប់ខ្ជួន។ MSC សូមរក្សាសិទ្ធិរបស់ខ្លួនចំពោះការធ្វើសវនកម្មផ្ទៃក្នុង ដើម្បីធានាបាននូវការអនុលោមតាមបទដ្ឋានដែលបរិយាយនៅក្នុងក្រមច្បាប់នេះរបស់និយោជិក និងទីភ្នាក់ងារទាំងអស់ ដោយមានជំនួយការរបស់ ផ្នែកសវនកម្មរបស់ក្រុមហ៊ុន MSC នៅហ្សឺណែវ និងផ្នែកផ្សេងៗទៀត ឬក្រុមសវនករពីខាងក្រៅបានយ៉ាងត្រឹមត្រូវ។ MSC សូមលើកទឹកចិត្តឲ្យបណ្តាទីភ្នាក់ងាររបស់ខ្លួនអនុវត្តក្រមច្បាប់ដោយអនុម័តតាម និងអនុវត្តនូវគោលការណ៍ និងគោលនយោបាយ (ផែនការ) បន្ថែមចំពោះលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមច្បាប់នេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏គ្មានករណីដែលគោលការណ៍ និងគោលនយោបាយ (ផែនការ) បន្ថែមនឹងមិនវិវាទគ្នា ឬមានលក្ខណៈអនុគ្រោះជាងក្រមច្បាប់នេះដែរ។ គោលការណ៍ និងគោលនយោបាយ (ផែនការ) បន្ថែមទាំងអស់ នឹងមានការផ្ញើ ទៅកាន់ ក្រុមការងារអនុវត្តន៍ច្បាប់របស់ MSC នៅហ្សឺណែវសម្រាប់ការពិនិត្យមើលឡើងវិញ និងការយល់ព្រម ឬឯកភាពរបស់ពួកគេ។ ករណីនៅមានភាពខុសគ្នាដែលបណ្តាលមកពីច្បាប់ ឬបទបញ្ញត្តិច្បាប់ក្នុងប្រទេស ក្រមច្បាប់នេះ (គោលការណ៍ និងគោលនយោបាយបន្ថែម) និងលក្ខខណ្ឌក្នុងប្រទេសដែលមួយណាក៏ដោយដែលកំណត់បាននូវបទដ្ឋានក្រមសីលធម៌ខ្ពស់បំផុត ត្រូវតែមានការអនុវត្ត។

និយោជិកម្នាក់មានទំនួលខុសត្រូវលើ:

- ការយល់ដឹង ឆ្លើយតប ឬបំពេញបានតាមបទដ្ឋានដែលមានបរិយាយនៅក្នុងក្នុងក្រមច្បាប់នេះ
- ការបន្តជ្រាបព័ត៌មានដោយខ្លួនឯង និងដឹងអំពីព័តមានបច្ចុប្បន្នភាពមួយចំនួន និង
- ការព្យាយាមចូលរៀនក្នុងវគ្គបណ្តុំបណ្តុះបណ្តាលសំខាន់ៗជាប់ទាក់ទងដែលមានគោលបំណងលើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពីបទដ្ឋានដែលមានយោងនៅក្នុងក្រមច្បាប់នេះ។

លើសពីរនេះការទទួលខុសត្រូវបន្ថែមនានាអាស្រ័យលើនិយោជិកដែលទទួលខុសត្រូវលើការមើលខុសត្រូវផ្សេងៗទៀតដើម្បី:

- ដើរតួនាទីជាគំរូនៅក្នុងការអនុលោមតាមលិខិត និងស្មារតីនៃក្រមច្បាប់នេះ
- ធានាឲ្យបានថា និយោជិកទាំងអស់ដែលនៅក្រោមការមើលខុសត្រូវរបស់ពួកគេមានការយល់ដឹងអំពី និងទទួលបានការហ្វឹកហ្វឺនអំពីរបៀបអនុវត្តក្រមច្បាប់នេះរួចហើយ
- មើលខុសត្រូវ និងពិនិត្យតាមដានលើការប្រតិបត្តិតាមគោលការណ៍របស់បុគ្គលិកខ្លួនដែលមានដាក់ចេញនៅក្នុងក្រមច្បាប់នេះ និង
- បញ្ឈប់ប្រព្រឹត្តទាំងឡាយណាដែលរំលោភក្រមច្បាប់នេះ និងរាយការណ៍អំពីការប្រព្រឹត្តទៅអ្នកអនុវត្តក្រមច្បាប់ដែលត្រូវរាយការណ៍វាប្រាប់ ទៅ ក្រុមការងារអនុវត្តន៍ច្បាប់របស់ MSC នៅហ្សឺណែវ។ បុគ្គលិកនិយោជិកដែលកំពុងធ្វើការនៅទីក្រុងហ្សឺណែវនៃប្រទេសស្វីស ត្រូវរាយការណ៍ដោយផ្ទាល់ប្រាប់ទៅក្រុមការងារអនុវត្តន៍ច្បាប់របស់ MSC នៅហ្សឺណែវ។

## ការបកស្រាយក្រមច្បាប់

គោលបំណងនៃក្រមច្បាប់នេះ មិនមែនដើម្បីរ៉ាប់រងលើកាលៈទេសៈទាំងអស់ ឬរំពឹងទុកលើរាល់ស្ថានភាពដែលអាចនឹងកើតមានឡើងនោះទេ។ ជាជំនួស វាបរិយាយអំពីគោលការណ៍ និងគោលនយោបាយ (ផែនការ) សម្រាប់អនុវត្តន៍ការងារអាជីវកម្មរបស់ MSC ក្នុងលក្ខណៈមានក្រមសីលធម៌មួយ។ នៅពេលកំពុងប្រឈមនឹងស្ថានភាពដែលមិនមានការលើកមកនិយាយឲ្យបានជាក់លាក់ដោយក្រមច្បាប់នេះ និយោជិកត្រូវរក្សាការគោរពបទដ្ឋានក្រមសីលធម៌ឲ្យបានខ្ពស់ដែលមានការប្រកាសនៅក្នុងឧស្សាហកម្មនេះ។ ស្ថានភាពនានាដែលមិនមានការរ៉ាប់រង ឬការផ្សាយនៅក្នុងក្រមច្បាប់នេះ ត្រូវតែមានការបញ្ជូនបន្តទៅកាន់អ្នកអនុវត្តច្បាប់ដែលត្រូវរាយការណ៍វាប្រាប់ ទៅ ក្រុមការងារអនុវត្តន៍ច្បាប់របស់ MSC នៅហ្សឺណែវ។ បុគ្គលិកនិយោជិកដែលកំពុងធ្វើការនៅទីក្រុងហ្សឺណែវនៃប្រទេស្វីស ត្រូវបញ្ជូនបន្តដោយផ្ទាល់ទៅក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។

បើនិយោជិតម្នាក់មិនច្បាស់អំពីថាតើការប្រព្រឹត្តរបស់ខ្លួននឹងមានផ្ទុយទៅនឹងក្រមច្បាប់នេះឬអត់ គេគប្បីសួរខ្លួនឯងនូវសំណួរសាមញ្ញៗមួយចំនួនដូចតទៅ:

- តើសកម្មភាព ឬទង្វើនេះមានលក្ខណៈស្របច្បាប់ ឬអនុលោមតាមក្រមច្បាប់នេះឬទេ?
- តើវានឹងមិននាំឲ្យអន្តរាយដល់ក្រុមហ៊ុន MSC ឬដល់រូបខ្ញុំឬទេ បើមានគេដឹងអំពីការប្រព្រឹត្តនេះ?
- តើខ្ញុំចង់ឲ្យមានការបោះពុម្ពផ្សាយសកម្មភាព ឬទង្វើរបស់ខ្ញុំនៅទំព័រមុខនៃកាសែតឬ?
- តើខ្ញុំនឹងចង់ឲ្យមានមនុស្សម្នាក់ប្រព្រឹត្តតាមរបៀបនេះដូចខ្ញុំឬទេ?

បើចម្លើយចំពោះសំណួរទាំងនេះគឺ “ទេ” នោះសកម្មភាព ឬទង្វើនេះនឹងត្រូវបានគេចាត់ទុកថាមិនអនុលោមតាមក្រមច្បាប់នេះទេ ហើយមិនត្រូវមានការប្រកាន់យកឡើយ។ បើអ្នកនៅតែមិនច្បាស់អំពីចម្លើយនេះ ពេលនោះអ្នកត្រូវទាក់ទាក់ទៅអ្នកអនុវត្តក្រមច្បាប់របស់អ្នក។ បើបញ្ហាពុំអាចមានការដោះស្រាយបានដោយអ្នកអនុវត្តក្រមច្បាប់នេះ អ្នកអនុវត្តក្រមច្បាប់នោះត្រូវប្រឹក្សាយោបល់ជាមួយនឹងក្រុមការងារអនុវត្តន៍របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។ បុគ្គលិកនិយោជិកដែលកំពុងធ្វើការនៅទីក្រុងហ្សឺណែវនៃប្រទេស្វីស ត្រូវបញ្ជូនបន្តដោយផ្ទាល់ទៅក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។ ព័ត៌មានទំនាក់ទំនងលម្អិតរបស់ ក្រុមការងារអនុវត្តន៍ច្បាប់របស់ MSC នៅហ្សឺណែវ សម្រាប់ការសាកសួរសំណួរទាក់ទងនឹងក្រមច្បាប់នេះ គេអាចរកមើលឃើញមាននៅលើInternet ឬ Website ក្រុមហ៊ុន MSC បាន។ និយោជិកមានសិទ្ធិលើកយកមកចោទសួរនូវសំណួរណាមួយតាមរយៈE-mailលដែលមានអាសយដ្ឋាន ethic@msc.com។

## ការរាយការណ៍អំពីការប្រព្រឹត្តខុសឆ្គង

ការប្រព្រឹត្តខុសឆ្គងរួមមាន (តែមិនកំណត់ចំពោះ) អំពើពុករលួយ, អំពើមិនស្របច្បាប់, ការសូកប៉ាន់ (ការស៊ីសំណូក), ការលួច ឬការប្រើប្រាស់ខុសចំពោះទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន MSC, ការបោកបន្លំ, ការបង្ខិតបង្ខំ, ការធ្វើខុសណាមួយ, ការខកខានបំពេញកាតព្វកិច្ចដោយចេតនា, ឬការរំលោភក្រមច្បាប់នេះ ឬគោលនយោបាយ និងទម្រង់ណាមួយរបស់ក្រុមហ៊ុន MSC។

ស្របតាមគុណតម្លៃជាស្នូលរបស់ក្រុមហ៊ុន MSC លទ្ធភាពបញ្ចេញមតិយោបល់គឺជាសសរគោលមួយសម្រាប់ការកសាងបាននូវវប្បធម៌នៃកន្លែងធ្វើការដែលបើកចំហ និងមានទំនួលខុសត្រូវខ្ពស់មួយ។ តាមអំណាយប្រើប្រាស់របស់ពួកគេ និយោជិកមានកម្មវិធីឧបករណ៍នៅអនឡាញមួយដែលគេហៅថា៖ “បណ្តាញបញ្ចេញមតិយោបល់របស់ MSC” ដែលចេញចូលប្រើបានInternetរបស់ MSC ដើម្បីរាយការណ៍អំពីការប្រព្រឹត្តខុសឆ្គងណាមួយបានគ្រប់ពេល។

ត្រូវមានការរាយការណ៍ឲ្យបានឆាប់រហ័សនូវការប្រព្រឹត្តខុសឆ្គងណាមួយដែលបានកើតមានឡើង។ និយោជិកទទួលបានការលើកទឹកចិត្តកម្មវិធីឧបករណ៍បញ្ចេញមតិយោបល់របស់ MSC នេះយ៉ាងខ្លាំង និងជាជំនួស រាយការណ៍ប្រាប់ទៅអ្នកអនុវត្តក្រមច្បាប់ ឬទៅក្រុមការងារអនុវត្តន៍ច្បាប់របស់ MSC នៅហ្សឺណែវ ដោយវាអាចនឹងឆ្លើយតបបាន។ បើការរាយការណ៍អំពីការប្រព្រឹត្តខុសឆ្គងបង្កើតនូវជម្លោះផលប្រយោជន៍ដល់អនុវត្តក្រមច្បាប់នេះ បញ្ហានេះត្រូវមានការបញ្ជូនទៅកាន់ក្រុមការងារអនុវត្តន៍ច្បាប់របស់ MSC នៅហ្សឺណែវ ឬតាមបណ្តាញបញ្ចេញមតិយោបល់របស់ MSC។ បុគ្គលិកនិយោជិកកំពុងធ្វើការនៅទីក្រុងហ្សឺណែវនៃប្រទេស្វីស ត្រូវបញ្ជូនបន្តដោយផ្ទាល់ទៅកាន់ក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ ឬ ទៅកាន់បណ្តាញបញ្ចេញមតិយោបល់របស់ MSC។

នៅពេលកំពុងរាយការណ៍អំពីការប្រព្រឹត្តខុសឆ្គង និយោជិកអាចសម្រេចបង្ហាញអត្តសញ្ញាណខ្លួនឯង ឬរក្សាភាពអនាមិកដោយយោងតាមច្បាប់នានាដែលពាក់ព័ន្ធ។ មិនត្រូវមានការសងសឹកប្រឆាំងនិយោជិកដែលធ្វើរបាយការណ៍មួយដោយសុទ្ធចិត្តឡើយ។

MSC ចាប់យកការចោទប្រកាន់អំពីរំលោភបំពានយ៉ាងហ្មត់ចត់បំផុត ហើយត្រូវស៊ើបអង្កេតការចោទប្រកាន់នីមួយៗយ៉ាងត្រឹមត្រូវ។ ការខកខានណាមួយចំពោះការអនុលោមតាមក្រមច្បាប់នេះ អាចនាំឲ្យមានការដាក់ចំណាត់ការវិន័យរហូតដល់ និងរួមទាំងការបញ្ឈប់ការងារ ឬកិច្ចសន្យាមួយចំនួនផ្សេងទៀត ក៏ដូចជាលទ្ធភាពនៃការផ្តន្ទាទោសរដ្ឋប្បវេណី ឬព្រហ្មទណ្ឌផងដែរ។





# បទដ្ឋាននៃការប្រតិបត្តិ

MSC គឺជាក្រុមហ៊ុនមួយដែលផ្ដល់សេវាកុងតឺន័រលើពិភពលោកតាមបណ្ដាញមួយដែលមានច្រកផ្លូវពាណិជ្ជកម្មចំនួន 200 ដែលចូលដល់កំពង់ផែកុងតឺន័រចំនួន 340។ ដោយសារវត្តមានជាអន្តរជាតិដែលរួបរួមគ្នា និងកំពុងរីកចម្រើនឥតដាច់របស់ក្រុមហ៊ុន MSC និយោជិកទាំងអស់ត្រូវតែអនុលោមតាមច្បាប់ដែលពាក់ព័ន្ធ, បទបញ្ញត្តិច្បាប់ និងវិធានច្បាប់, គោលការណ៍ណែនាំជាផ្លូវការ, ក្រមច្បាប់នៃវិធីអនុវត្តន៍ប្រសើរបំផុត, ភាពជាដៃគូជាមួយនឹងរដ្ឋាភិបាល និងបទដ្ឋាន ISO នៅគ្រប់ពេលដែលសំខាន់ជាប់ទាក់ទង។

ជាការបន្ថែម ក្រមច្បាប់នេះចែងនូវបទដ្ឋានជារួមនៃការប្រព្រឹត្តដែលទទួលបានការយល់ព្រម ឬអនុម័ត ដោយមិនគិតដល់ទីកន្លែងរបស់និយោជិកឡើយ។ បទដ្ឋានទាំងនេះបំពេញបន្ថែម និងអាចប្រព្រឹត្តទៅបានត្រឹមត្រូវលើសពីការអនុលោមតាមច្បាប់ និងបទបញ្ញត្តិច្បាប់នានានៅតាមបណ្ដាប្រទេសដែលក្រុមហ៊ុន MSC ធ្វើប្រតិបត្តិការ។

# បរិស្ថាន

MSC ខិតខំស្វះស្វែងឲ្យក្លាយខ្លួនជាក្រុមហ៊ុននាំមុខគេមួយនៅក្នុងដំណើរការដឹកជញ្ជូនប្រកបដោយនិរន្តរភាពផ្នែកបរិស្ថាន។ ដើម្បីសម្រេចឲ្យបាននូវគោលបំណងដ៏សំខាន់ជាក់លាក់នេះ ក្រុមហ៊ុន MSC មានការប្តេជ្ញាចិត្តចំពោះ:

- ការកាត់បន្ថយផលប៉ះពាល់លើបញ្ហាបម្រែបម្រួលធាតុអាកាសដោយធ្វើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (ជាឧទាហរណ៍ ការប្រើប្រអប់ឧបករណ៍វាយតម្លៃបរិស្ថាន (Eco Toolbox) របស់ MSC) ដែលវាស់វែងលើកម្រិតនៃការប្រើថាមពល និងឥន្ធនៈរបស់នាវា
- ការការពារជីវៈចម្រុះ និងសត្វក្នុងទឹក (ជាឧទាហរណ៍ ការស្នើសុំឲ្យមានគ្រោងនៃនាវាដែលកសាងឡើងថ្មីៗដែលត្រូវចាប់ផ្តើមឲ្យមានប្រតិបត្តិការ និងបំពេញមុខងារតាមដែលបានគ្រោងបង្កើតឡើងជាមួយនឹងក្រុមហ៊ុន MSC មានការលាបពណ៌ដែលបង្ហាញឲ្យឃើញនូវការវាយតម្លៃខ្ពស់ចំពោះបរិស្ថាន)
- ការវិនិយោគលើបច្ចេកវិជ្ជានវានុវត្តន៍ (កែប្រែថ្មី) ដែលនឹងកាត់បន្ថយតម្រូវការរបស់មនុស្សលើធម្មជាតិនៅក្នុងសេវាកម្មរបស់ក្រុមហ៊ុនយើង (ជាឧទាហរណ៍ ការកាត់បន្ថយប្លង់នៃគ្រោងសម្រាប់នាវាដែលកសាងឡើងថ្មីៗដែលនឹងលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើឥន្ធនៈ ហើយដែលនឹងប្រើបច្ចេកវិជ្ជាទាំងនេះដើម្បីធ្វើអោយប្រសើរឡើងនូវនាវានានាដែលមានកន្លងមក)
- ការអនុវត្តវិធីគ្រប់គ្រង និងប្រព័ន្ធប្រតិបត្តិការដែលមានជាអាទិ៍ តាមរយៈការធ្វើឲ្យទៅជាប្រព័ន្ធឌីជីថល និងវិស្វកម្មកែច្នៃ ដើម្បីបង្កើនប្រសិទ្ធភាពឲ្យបានខ្ពស់បំផុត និងជៀសវាងបញ្ហាកំហុសរបស់មនុស្ស (ជាឧទាហរណ៍ ការប្រើប្រព័ន្ធផ្លាស់ផ្លាស់ប្តូរផែនការដែលមានកម្រិតនិងប្រសិទ្ធភាពខ្ពស់ខ្ពស់ (Intelligent Planning Exchange System – IPX) ដែលគ្រោងប្រើនិងរក្សាទុកទំនិញដែលមានគ្រោះថ្នាក់ដោយស្វ័យប្រវត្តិ
- ការលើកទឹកចិត្តឲ្យមានគម្រោងនិស្សរណកម្មនៅក្នុងក្រុមហ៊ុន MSC និងនៅតាមបណ្តាទីភ្នាក់ងារ (ជាឧទាហរណ៍ ការធ្វើនិស្សរណកម្មក្រដាស, ដបប្លាស្ទិក, គ្រឿងបរិក្ខារព័ត៌មានវិទ្យា (IT), និងប្រដាប់ផ្ទុកទឹកខ្មៅ)។

និយោជិកគ្រប់ៗរូបត្រូវមានឆន្ទៈគិតពិចារណាលើគំនិតគិតឃើញថ្មីៗអំពីបញ្ហានវានុវត្តន៍ និងការផ្លាស់ប្តូរ។ យើងសូមលើកទឹកចិត្តឲ្យក្រុមអ្នកគ្រប់គ្រងស្តាប់នូវគំនិតគិតឃើញរបស់និយោជិកអំពីរបៀបកាត់បន្ថយការប្រើប្រាស់ប្រភពធនធាន។





# សិទ្ធិមនុស្ស និងបទដ្ឋានប្រើប្រាស់កម្លាំងពលកម្ម

MSC គាំទ្រ និងខិតខំស្វះស្វែងលើកកម្ពស់អភិបាលកិច្ចក្រុមហ៊ុនឲ្យបានល្អជាប់ជានិច្ច ដែលនឹងរួមចំណែកដល់ការទទួលខុសត្រូវផ្នែកសង្គម និងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពកាន់តែទូលំទូលាយដូចដែលបានរំពឹងទុកដោយសហគមន៍អន្តរជាតិ។ ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ ក្រុមហ៊ុន MSC យ៉ាងហោចណាស់ ត្រូវគោរពតាមច្បាប់ វិធានច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធទាំងអស់នៃបណ្តាប្រទេសដែលកំពុងយើងកំពុងធ្វើប្រតិបត្តិការ។ បន្ថែមលើសពីនេះ ការក្លាយជាផ្នែកមួយនៃវិស័យដឹកជញ្ជូនជាអន្តរជាតិ ដែលជាផ្នែកមួយនៃឧស្សាហកម្មដែលមានការធ្វើនិយតកម្មខ្លាំងបំផុតនៅកម្រិតថ្នាក់ពិភពលោក ការប្តេជ្ញាចិត្តរបស់ MSC ចំពោះការលើកកម្ពស់វិធីអនុវត្តន៍ការងារអាជីវកម្មប្រកបដោយទំនួលខុសត្រូវ និងត្រឹមត្រូវដែលត្រូវប្រកាន់យកឲ្យបានខ្ជាប់ខ្ជួនចំពោះ និងធ្វើឲ្យមានគុណសម្បត្តិចំពោះគោលការណ៍ និងបទដ្ឋាននៃការគោរពសិទ្ធិមនុស្ស និងការប្រើប្រាស់កម្លាំងពលកម្មដែលមានការទទួលស្គាល់ជាអន្តរជាតិ។

ទាក់ទងនឹងបញ្ហានេះ និងដោយអនុវត្តន៍តាមគុណតម្លៃជាស្នូលរបស់ MSC, វិធីដោះស្រាយបញ្ហាអាស្រ័យលើគោលការណ៍របស់កតិកាសញ្ញាស្តីពីការលើកទឹកចិត្តឲ្យក្រុមហ៊ុនទូទាំងពិភពលោកអនុម័តគោលនយោបាយទទួលខុសត្រូវប្រកបដោយនិរន្តរភាព និងផ្នែកសង្គម ហើយរាយការណ៍អំពីការអនុវត្តរបស់ខ្លួននៃអង្គការសហប្រជាជាតិ (United Nations Global Compact) ក៏ដូចជាគោលការណ៍ដឹកនាំលើបញ្ហាពាណិជ្ជកម្ម និងសិទ្ធិមនុស្ស (UNGPs) ក្រុមហ៊ុន MSC គាំទ្រដល់ការគោរពគោលការណ៍សំខាន់ៗជាប់ទាក់ទងដែលមានចែងនៅក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ក៏ដូចជាការគោរពបញ្ញត្តិច្បាប់ និងអនុសាសន៍សំខាន់ៗជាប់ទាក់ទងនឹងលិខិតុបករណ៍ និងអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ (ILO) ផងដែរ។ លើសពីនេះ ក្នុងនាមជាក្រុមហ៊ុនដឹកជញ្ជូនអន្តរជាតិមួយ MSC អនុលោមតាមវិសាលភាពនៃបទដ្ឋាន និងលក្ខខណ្ឌអន្តរជាតិដែលកំណត់ដោយអនុសញ្ញាស្តីពីការប្រើកម្លាំងពលកម្មតាមសមុទ្រដែលបានអនុម័តនៅថ្នាក់អន្តរជាតិដោយអង្គការសហប្រជាជាតិដែលមានជាអាទិ៍ អនុសញ្ញាស្តីពីការប្រើកម្លាំងពលកម្មតាមសមុទ្ររបស់អង្គការ ILO ឆ្នាំ 2006 (MLC, 2006)។

## ការមិនរើសអើង

ដោយអនុវត្តន៍តាមគុណតម្លៃជាស្នូលរបស់ខ្លួន ក្រុមហ៊ុន MSC មានការប្តេជ្ញាចិត្តដាច់ខាតចំពោះការគាំទ្រនូវឱកាសទទួលបានការងារស្មើៗភាពគ្នា តាមរយៈការធានាឲ្យបានថា គ្រប់ទិដ្ឋភាពនៃវិធីអនុវត្តន៍ការជួល និងការផ្តល់ការងារ គឺអាស្រ័យលើមូលដ្ឋាននៃគុណសម្បត្តិ និងសមត្ថភាពទាក់ទងនឹងការងារ។

ក្រុមហ៊ុន MSC គោរពចំពោះលក្ខណៈពិសេសរបស់បុគ្គលម្នាក់ៗ និងមិនអត់ឱនឲ្យដល់ការរើសអើងដែលអាស្រ័យលើមូលដ្ឋានណាមួយ (ដូចជា ភេទ, ជាតិសាសន៍, ពណ៌សម្បុរ, សាសនា, ភាសា, ដើមកំណើតជាតិពន្ធ, អាយុ, ពិការភាព, សមាជិកភាពអង្គការនយោបាយ ឬមនោគមន៍វិជ្ជា, សមាជិកភាពអង្គការសហជីព, ស្ថានភាពគ្រួសារ ឬការទទួលខុសត្រូវក្នុងគ្រួសារ, ទំនោរភេទ ឬអត្តសញ្ញាណភេទ) ឡើយ។ ការយកចិត្តទុកដាក់ជាពិសេសមានការផ្តល់ឲ្យដល់ប្រភេទកម្មករកម្មការនីដែលងាយរងគ្រោះដូចដែលបានរំពឹងទុកដោយសហគមន៍អន្តរជាតិ។

ក្រុមហ៊ុន MSC និងទីភ្នាក់ងារនានារបស់ខ្លួន អនុលោមយ៉ាងម៉ឺងម៉ាត់តាមច្បាប់ជាតិ, លក្ខខណ្ឌច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធ និង/ឬបទដ្ឋានឧស្សាហកម្មសំខាន់ៗជាប់ទាក់ទងដែលមានប្រសិទ្ធភាពលប់លើសលប់ និងធានា (យ៉ាងហោចណាស់ត្រឹមកម្រិតអប្បរមា) សិទ្ធិរបស់និយោជិកលើគ្រប់ទិដ្ឋាននៃការងារ។ ទាំងនេះរួមមានសំណើសុំធ្វើការងារ, ការដំឡើងតួនាទី, រង្វាន់, ប្រាក់ឈ្នួល, ប្រាក់ធ្វើការលើសម៉ោង, ចំនួនម៉ោងធ្វើការ, ការឈប់សម្រាក, អត្ថប្រយោជន៍នានា, លទ្ធភាពចូលរៀនក្នុងវគ្គបណ្តុះបណ្តាល, ការចាត់តាំងការងារ, អត្ថប្រយោជន៍ផ្នែកសង្គម, ចំណាត់ការកែតម្រូវ និងដាក់វិន័យ, ការបញ្ឈប់ការងារ ឬការចូលនិវត្តន៍។



## ការគោរពគ្នាទៅវិញទៅមក និងការគោរពមនុស្សស្មើៗភាពគ្នា

MSC ជឿជាក់ថា មនុស្សម្នាក់ៗ (រួមទាំងអតិថិជន, ដៃគូពាណិជ្ជកម្ម/អាជីវកម្ម និងភាគីពាក់ព័ន្ធទាំងអស់ដែលយើងមានទំនាក់ទំនងគ្នា) សមនឹងទទួលបាននូវការគោរព ភាពយុត្តិធម៌ និងសេចក្ដីថ្លៃថ្នូរ។

ការទទួលខុសត្រូវនេះអាស្រ័យលើនិយោជិកគ្រប់ៗរូប។

## ភាពចម្រុះ

ភាពចម្រុះរបស់និយោជិកតំណាងឲ្យធនធានមួយក្នុងចំណោមធនធានដ៏ធំបំផុតរបស់ក្រុមហ៊ុន MSC និងរួមចំណែកដល់ការបន្តទទួលបានជោគជ័យរបស់ខ្លួន។

MSC រំពឹងថា និយោជិករបស់ខ្លួននឹងវាយតម្លៃខ្ពស់សមត្ថភាពពិសេសៗដាច់ដោយឡែកៗ, ចំណុចខ្លាំង និងជំនាញរបស់មនុស្សម្នាក់ៗ និងគាំទ្រគ្នាទៅវិញទៅមក នៅខណៈពេលកំពុងក្រសោបយក និងគោរពចម្រុះភាពផ្នែកវប្បធម៌ និងប្រពៃណីក្នុងស្រុក។

## ការយាយី និង ការប្រព្រឹត្តបំពានផ្សេងៗទៀត

MSC មិនអត់ឱនចំពោះការយាយីរំខាន ឬការប្រព្រឹត្តបំពានតាមទម្រង់ណាមួយដែលមានជាអាទិ៍ ការបង្ខិតបង្ខំដោយពាក្យសំដី ឬដោយផ្លូវចិត្ត, ទណ្ឌកម្មលើរូបរាងកាយ និងការរំខានយាយីផ្លូវភេទឡើយ។ ការយាយី និងការប្រព្រឹត្តបំពាន អាចមានជាអាទិ៍ ទង្វើ ឬការគម្រាមកំហែងប្រើអំពើហិង្សាដល់មនុស្សម្នាក់ផ្សេងទៀត (រួមមាន កាយវិការ, ការសម្លុត, "ការចំអក" ឬការបំភិតបំភ័យ, ទំនាក់ទំនងភាសា និងជារូបវ័ន្ត) ក៏ដូចជាការធ្វើឲ្យខូចខាតដោយអចេតនាដល់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន MSC និងបណ្ដាទីភ្នាក់ងាររបស់ខ្លួន ឬទ្រព្យសម្បត្តិរបស់មនុស្សម្នាក់ផ្សេងទៀត, ឬឥរិយាបថណាមួយផ្សេងទៀតដែលបណ្ដាលឲ្យអ្នកផ្សេងៗគិតថាគ្មានសុវត្ថិភាពនៅក្នុងកន្លែងធ្វើការរបស់ក្រុមហ៊ុន MSC ឬបណ្ដាទីភ្នាក់ងាររបស់ខ្លួន។

## សេរីភាពចូលរួមសមាគមន៍

ក្រុមហ៊ុន MSC ទទួលស្គាល់សិទ្ធិសេរីភាពនៃការចូលរួមសមាគមន៍របស់និយោជិកទាំងអស់។ ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិច្បាប់ពាក់ព័ន្ធ និយោជកទាំងអស់ត្រូវមានសិទ្ធិចូលរួម ឬមិនចូលរួម និងបង្កើតសហជីពដោយគ្មានការភ័យខ្លាចចំពោះការបំភិតបំភ័យ ឬការផ្ដាញ់តបឡើយ។



## ពលកម្មដោយបង្ខំ និងទាសភាពនាសម័យទំនើប

MSC មានការប្តេជ្ញាចិត្តចំពោះការធានាឲ្យបាននូវសេចក្តីថ្លៃថ្នូររបស់មនុស្សជាមូលដ្ឋាននៃនិយោជិកទាំងអស់របស់ខ្លួន។

ដើម្បីសម្រេចឲ្យបាននូវគោលបំណងនេះ ក្រុមហ៊ុន MSC ហាមឃាត់ចំពោះការធ្វើអាជីវកម្មលើផ្នែកសេដ្ឋកិច្ច និងសង្គមរបស់មនុស្សម្នាក់ដោយមនុស្សម្នាក់ផ្សេងទៀតដើម្បីផលចំណេញផ្ទាល់ខ្លួន និង/ឬផ្នែកពាណិជ្ជកម្ម, ពលកម្មដោយបង្ខំ និងពលកម្មដែលកំណត់លក្ខខណ្ឌដោយច្បាប់/ដោយស្ម័គ្រចិត្តដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីពលកម្មដោយបង្ខំ-C029 របស់អង្គការ ILO ឆ្នាំ 1930 (លេខ 29), ការប្រើប្រាស់កម្លាំងពលកម្មនៅពន្ធនាគារ និងទម្រង់ណាមួយនៃទាសភាព ឬភាពត្រូវគេជិះជាន់ដែលមានជាអាទិ៍ ពលកម្មទាសភាព និងការជួញដូរមនុស្ស។

## ពលកម្មកុមារ និងកិច្ចការពារ កម្មករក្មេងៗ

ក្រុមហ៊ុន MSC ហាមឃាត់ដាច់ខាតចំពោះការប្រើប្រាស់ពលកម្មកុមារ និងប្រកាន់ខ្ជាប់ចំពោះការអនុវត្តតាមបទដ្ឋានអន្តរជាតិសំខាន់ៗជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិកុមារដែលមានប្រភេទដូចជា អនុសញ្ញាស្តីពីអាយុធ្វើពលកម្មជាមធ្យម-C138 របស់អង្គការ ILO ឆ្នាំ 1973 (លេខ 138), អនុសញ្ញាស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ-C182 របស់អង្គការ ILO ឆ្នាំ 1999 (លេខ 182) និងអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ (UNCRC)។

នៅពេលកើតមានភាពខុសគ្នា ឬវិវាទកើតឡើងលើបទដ្ឋាន ក្រុមហ៊ុន MSC អនុវត្តតាមបទដ្ឋានកម្រិតខ្ពស់បំផុត។ ក្រុមហ៊ុន MSC គាំទ្រ និងវិនិយោគលើកម្មវិធីបណ្តុះបណ្តាលនៅតាមផ្នែកផ្សេងៗនៃពិភពលោក ប្រយោជន៍ផ្តល់នូវកម្មវិធីអភិវឌ្ឍន៍ផ្ទាល់ខ្លួន និយោជិកឲ្យដល់និយោជិតក្មេងៗ។ ដោយយោងតាមសេចក្តីថ្លែងការណ៍ត្រីភាគីស្តីពីគោលការណ៍ពាក់ព័ន្ធនឹងក្រុមហ៊ុនចម្រុះជាតិសាសន៍ និងគោលនយោបាយផ្នែកសង្គម (សេចក្តីថ្លែងការណ៍ MNE-ការបោះពុម្ពលើកទី 5 ឆ្នាំ 2017) របស់អង្គការ ILO នៅក្នុងសំណើផ្តល់ឱកាសបែបអស់ទាំងនេះ ក្រុមហ៊ុន MSC ដើរតួនាទីដោយយោងតាមច្បាប់, បទបញ្ញត្តិច្បាប់ និងលក្ខខណ្ឌច្បាប់ជាតិដែលពាក់ព័ន្ធ ដោយធានាឲ្យបាននូវការគោរពសិទ្ធិកុមារដែលត្រូវចូលរៀន និង/ឬបញ្ចប់ការសិក្សានៅសាលាដែលកំណត់លក្ខខណ្ឌដោយច្បាប់។

ដោយការក្លាយជាក្រុមហ៊ុនដឹកជញ្ជូនអន្តរជាតិមួយ ជួសមុខឲ្យនាវិកតាមសមុទ្រ ក្រុមហ៊ុន MSC ប្រកាន់ខ្ជាប់នូវបញ្ញត្តិច្បាប់សំខាន់ៗជាប់ទាក់ទងដែលមានចែងនៅក្នុងអនុសញ្ញាពាក់ព័ន្ធរបស់អង្គការ ILO ដែលមានជាទិ៍ អនុសញ្ញាស្តីពីពលកម្មតាមសមុទ្ររបស់អង្គការILO ឆ្នាំ 2006 (MLC, 2006)។

## សហគមន៍ និង
## ការចូលរួមរបស់ភាគីពាក់ព័ន្ធ

រហូតមកដល់ពេលនេះ ក្រុមហ៊ុន MSC បានកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួនតាមរយៈការបង្កើតឲ្យមាន និងការរក្សានូវទំនាក់ទំនងនៅគ្រប់កម្រិតទាំងអស់ជាមួយនឹងអតិថិជន, ដៃគូអាជីវកម្ម/ពាណិជ្ជកម្មរបស់ខ្លួន, សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដ៏ច្រើនរបស់ខ្លួនដែលអាស្រ័យលើគុណតម្លៃ, ភាពស្មោះត្រង់ និងការជឿទុកចិត្តគ្នាទៅវិញទៅមករួមគ្នា។

ដោយមានទស្សនៈមួយចំពោះការចូលរួមចំណែកដល់ការបញ្ចូលឥទ្ធិពលវិជ្ជមានផ្នែកសេដ្ឋកិច្ចសង្គមក្នុងរយៈពេលយូរអង្វែង ក្រុមហ៊ុន MSC មានការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះការធ្វើអាជីវកម្ម/ពាណិជ្ជកម្មប្រកបដោយការទទួលខុសត្រូវមួយដែលគោរពដល់សិទ្ធិជាមូលដ្ឋានរបស់សហគមន៍មូលដ្ឋានដែលរួមមានប្រជាពលរដ្ឋមានកំណើតនៅតាមមូលដ្ឋានរបស់ខ្លួន ក៏ដូចជាក្រុមមនុស្សដែលងាយរងគ្រោះ និងមានផលវិបាកផ្សេងៗទៀតដែរ។

## ការគាំទ្រសិទ្ធិមនុស្ស

MSC លើកទឹកចិត្តឲ្យនិយោជិកចូលរួមចំណែកប្រើវិធីអនុវត្តន៍ប្រសើរបំផុតដែលប្រកបដោយការទទួលខុសត្រូវផ្នែកសង្គមដែលអាចនឹងជម្រុញឲ្យមានភាពជឿនលឿនលើការគោរពសិទ្ធិមនុស្ស នៅពេលបានចាត់ទុកថាសមស្រប និងដោយយោងតាមបទដ្ឋានអន្តរជាតិ និង/ឬផែនការអភិវឌ្ឍន៍ជាតិ តាមរយៈ:

- គំនិតផ្តួចផ្តើមជាក់លាក់ និងការស្រលាញ់មនុស្សជាតិរបស់ប្រទេស ឬតំបន់
- ការចូលរួម និងថ្លែងការគាំទ្រគោលនយោបាយជាសាធារណៈ
- ភាពជាដៃគូ និងចំណាត់ការជារួម

ការចូលរួមចំណែករបស់ក្រុមហ៊ុន MSC ចំពោះកិច្ចប្រឹងប្រែងបង្កើតសន្តិភាព និងសកម្មភាពជំនួយមនុស្សជាតិដែលមានជាអាទិ៍ តាមរយៈសកម្មភាពអាជីវកម្ម/ពាណិជ្ជកម្មសំខាន់ៗ ប្រកាន់ខ្ជាប់ខ្លួននូវ និងអនុលោមតាមបទបញ្ញត្តិច្បាប់អន្តរជាតិសំខាន់ៗជាប់ពាក់ព័ន្ធ។

## សុខភាព និងសុវត្ថិភាពការងារអាជីព

MSC ខិតខំស្វះស្វែងផ្តល់ឲ្យនិយោជិកនូវកន្លែងធ្វើការដែលប្រកបដោយសុវត្ថិភាព និងមានសុខភាពល្អ។ ដើម្បីបំពេញតាមគោលដៅនេះ ក្រុមហ៊ុន MSC:

- អនុលោមច្បាប់ស្តីពីកិច្ចការពារសុខភាព និងសុវត្ថិភាពដែលមានជាទី អនុសញ្ញាស្តីពីពលកម្មតាមសមុទ្រ ឆ្នាំ 2006 (MLC, 2006)
- អនុវត្តតាមវិធីការការពារសុវត្ថិភាពដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់សុវត្ថិភាពជាអន្តរជាតិ
- មានវិធីការតឹងរឹងចំពោះការដឹកជញ្ជូនទំនិញគ្រោះថ្នាក់។ MSC ដើរហួសវិធានការនានានានាដែលបានបង្កើតឲ្យមានឡើងនៅក្នុងក្រមច្បាប់អន្តរជាតិស្តីពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមសមុទ្រ និងសម្រាប់មុខទំនិញគ្រោះថ្នាក់ពិតប្រាកដខ្លួនបានស្នើសុំឲ្យអ្នកស្ទង់មតិឯករាជ្យពិនិត្យទំនិញនោះ ហើយ
- បង្កើតភាពជាដៃគូរជាមួយនឹងរដ្ឋាភិបាលនានាដើម្បីបង្កើនសន្តិសុខសុវត្ថិភាពសង្វាក់ផ្គត់ផ្គង់ (ឧទាហរណ៍ MSC អនុវត្តតាមបទដ្ឋាន C-TPAT)។

ជាទូទៅ នៅលើសមុទ្រ ម្ចាស់កប៉ាល់ទទួលខុសត្រូវជាចម្បងលើបញ្ហាសុខភាព និងសុវត្ថិភាពរបស់ក្រុមនាវិកតាមសមុទ្រទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ ក៏ជាទូទៅការទទួលខុសត្រូវពីមួយថ្ងៃទៅមួយថ្ងៃអាស្រ័យលើ ឬកំណត់ដោយអ្នកជំនាញដែរ។ និយោជិកក៏មានការទទួលខុសត្រូវផងដែរ: ពួកគេត្រូវអនុវត្ត ឬអនុលោមតាមវិធានការសុខភាព និងសុវត្ថិភាពក្នុងអាជីពដែលការដាក់ចេញជាបទបញ្ជា។ នៅលើគោក (ដូចគ្នានឹងនៅលើសមុទ្រ) ការទទួលខុសត្រូវលើបញ្ហាការពារសុខភាព និងសុវត្ថិភាព ក៏មានចែករំលែកគ្នាដែរ។ វិធានការការពារសុខភាព និងសុវត្ថិភាព មានការបង្កើតឡើងនៅក្នុងក្រុមហ៊ុន MSC និងបណ្តាទីភ្នាក់ងាររបស់ខ្លួននិយោជិកអនុវត្តតាមអង្គភាពទាំងនេះ។

ក៏ប៉ុន្តែ ការពង្រឹង ឬផ្តល់ការគាំទ្រឲ្យនិយោជិកទទួលខុសត្រូវចំពោះបញ្ហាការពារសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួននិយោជិកតគ្រប់ៗរូបមានសិទ្ធិដកខ្លួនពួកគេចេញពីស្ថានភាព ឬប្រតិបត្តិការប្រកបដោយគ្រោះថ្នាក់នានាបាន នៅពេលមានបញ្ហាគ្រោះថ្នាក់ធ្ងន់ធ្ងរប្រុងនឹងកើតឡើងចំពោះបញ្ហាសុខភាព និងសុវត្ថិភាព។

ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីលើកកម្ពស់ជានិច្ចនូវការបំពេញតួនាទីការពារសុខភាព និងសុវត្ថិភាពនៅក្នុងប្រតិបត្តិការរបស់ខ្លួន ក្រុមហ៊ុន MSC ធ្វើការស៊ើបអង្កេតករណីគ្រោះថ្នាក់ ឬក្បែរនឹងគ្រោះថ្នាក់នៅគ្រប់ពេលដែលមានការកំណត់ថាចាំបាច់តាមនីតិវិធីផ្ទៃក្នុងរបស់យើង។



# ការប្រឆាំងបទស៊ីសំណូក

នៅពេលកំពុងធ្វើអាជីវកម្មនៅកន្លែងណាមួយលើពិភពលោក ក្រុមហ៊ុន MSC មានការប្ដេជ្ញាចិត្តធ្វើអាជីវកម្មយ៉ាងត្រឹមត្រូវ និងប្រកាន់ខ្ជាប់នូវច្បាប់ប្រឆាំងបទស៊ីសំណូកដែលពាក់ព័ន្ធទាំងអស់ (រួមទាំងក្រមច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសស្វីស) និង (ក្នុងករណីដែលពាក់ព័ន្ធ ឬប្រើបាន) ច្បាប់អនុវត្តន៍ការប្រឆាំងអំពើពុករលួយនៅបរទេសរបស់ សរអ និងច្បាប់ប្រឆាំងបទស៊ីសំណូករបស់ចក្រភពអង់គ្លេសឆ្នាំ 2010។

MSC ហាមឃាត់ដាច់ខាតចំពោះអំពើពុករលួយ, បទផ្ដល់ និងទទួលសំណូក, និងការចំណាយលើការសម្របសម្រួលទាំងអស់។ ក្នុងច្បាប់ភាគច្រើនបំផុត ការប្រព្រឹត្តបែបនេះអាចនាំឲ្យមានការដាប់ពន្ធនាគារចំពោះបុគ្គលនានា និងការពិន័យធ្ងន់ធ្ងរចំពោះបុគ្គល និងអង្គភាពនានា។ MSC សូមរក្សាសិទ្ធិចាត់ការដាក់វិន័យចំពោះនិយោជិកទាំងឡាយណាដែលចូលរួមពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តបែបនេះ។ និយោជិកមិនត្រូវចូលរួមពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តបែបនេះជាដាច់ខាត។ និយោជិកមិនត្រូវចូលរួមពាក់ព័ន្ធជាមួយនឹងភ្នាក់ងារ, ទីប្រឹក្សា ឬអ្នកផ្គត់ផ្គង់ដែលជាភាគីទីបីជាដាច់ខាត បើមានហេតុផលដែលជឿជាក់ថា ភ្នាក់ងារ, ទីប្រឹក្សា ឬអ្នកផ្គត់ផ្គង់នោះ អាចនឹងព្យាយាមរំលោភបំពានលើគោលនយោបាយប្រឆាំងបទស៊ីសំណូករបស់ MSC។

បើមានការស្នើសុំឲ្យនិយោជិកចូលរួមនៅក្នុងការចំណាយលើការសម្របសម្រួល ពួកគេត្រូវតែបដិសេធដាច់ខាតចំពោះការចំណាយប្រាក់នេះ ហើយផ្ដល់ដំណឹងជាបន្ទាន់ទៅអ្នកអនុវត្តក្រមច្បាប់របស់ពួកគេ និង/ឬក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ ពីព្រោះវានឹងឆ្លើយឆ្លងបាន។ ការពិត ឬអង្គហេតុដែលការប្រាក់នេះមានសំណើជាមុនដោយភាគីផ្សេងទៀត មិនធ្វើឲ្យការប្រព្រឹត្តនេះស្របច្បាប់ទេ។ MSC មានគោលនយោបាយមិនអត់ឱនដាច់ចំពោះការចំណាយលើការសម្របសម្រួល វៀរលែងតែករណីដែលបញ្ហាសុខភាព និងសុវត្ថិភាពរបស់និយោជិកម្នាក់កំពុងស្ថិតក្នុងហានិភ័យ។

នៅពេលមានការអនុញ្ញាតឲ្យផ្ដល់ជំនូន/អំណោយ (ទាយជ្ជទាន) ទៅមន្ត្រីរដ្ឋាភិបាល វាងាយស្រួលណាស់ដែលនឹងឆ្លងរំលងចាប់ពីជំនូនមិនសូវមានតម្លៃ និងបដិសណ្ឋារកិច្ចរបស់ក្រុមហ៊ុនទៅរកអំពើពុករលួយ។ ជំនូនមិនសូវមានតម្លៃដែលមានការអនុញ្ញាតឲ្យក្នុងគោលនយោបាយរបស់ MSC រួមមានជំនូនផ្សព្វផ្សាយសេវារបស់ MSC ណាមួយ។ MSC នឹងមិនអត់ឱនចំពោះការប្រាក់សំណូកទៅឲ្យក្រុមមន្ត្រីរដ្ឋាភិបាលដែលមានជាអាទិ៍ការប្រព្រឹត្តទាំងឡាយណាដែលបន្លំជាជំនូននោះឡើយ។

ជំនូន/អំណោយ (ទាយជ្ជទាន) និងបដិសណ្ឋារកិច្ចរបស់ក្រុមហ៊ុនប្រភេទណាមួយដែលទទួលបាន ឬមានការឲ្យទៅ ឬដោយនិយោជិកម្នាក់ ត្រូវមានសេចក្ដីរាយការណ៍និងកំណត់ត្រាត្រឹមត្រូវ។ ជំនូន/អំណោយ (ទាយជ្ជទាន) និងបដិសណ្ឋារកិច្ចរបស់ក្រុមហ៊ុនប្រភេទណាមួយដែលទទួលបាន ឬមានការឲ្យដែលមានតម្លៃលើសពីកម្រិតកំណត់នៅក្នុងវិធីការសម្រាប់ជំនូន/អំណោយ (ទាយជ្ជទាន) & បដិសណ្ឋារកិច្ចរបស់ក្រុមហ៊ុនដូចដែលបាច្បាប់អនុវត្តន៍ត្រូវស្ថិតក្រោមការយល់ព្រម ឬឯកភាពរបស់ក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។



# ទំនាស់ផលប្រយោជន៍

ទំនាស់ផលប្រយោជន៍អាចនឹងកើតមានឡើងបាន ឧទាហរណ៍ នៅពេលនិយោជិកម្នាក់ចូលរួមពាក់ព័ន្ធនៅក្នុងប្រតិបត្តិអាជីវកម្មជាមួយនឹងភាគីទីបី (រួមមាន (តែមិនកំណត់ចំពោះ) អ្នកបញ្ជូនទំនិញ, ឈ្មួញកណ្តាល (អន្តរការី) និងអ្នកបើកបរក្រៅពីកប៉ាល់) ដែលនិយោជិក ឬសមាជិកក្រុមគ្រួសារមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬផ្ទាល់ខ្លួន (ឧទាហរណ៍ ជាម្ចាស់, ម្ចាស់ភាគហ៊ុន, សមាជិកក្រុមប្រឹក្សា, មន្ត្រី, និយោជិក ឬភ្នាក់ងារម្នាក់)។

និយោជិកមិនត្រូវធ្វើខ្លួនឲ្យជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពណាមួយដែលរំខាន ឬផ្លាស់ប្តូរចំពោះការវិនិច្ឆ័យលើការបំពេញកាតព្វកិច្ចឡើយ។

គោលនយោបាយគ្រប់គ្រងទំនាស់ផលប្រយោជន៍របស់ក្រុមហ៊ុន MSC ផ្តល់នូវគោលការណ៍អំពីរបៀបកំណត់ប្រភេទ, រាយការណ៍ និងគ្រប់គ្រងស្ថានភាពពិតប្រាកដនៃទំនាស់ផលប្រយោជន៍ធំៗ។ និយោជិកទាំងអស់ចាំបាច់ត្រូវអានឲ្យបានច្បាស់លាស់ និងអនុវត្ត ឬអនុលោមតាមឲ្យបានហ្មត់ចត់នូវគោលនយោបាយគ្រប់គ្រងទំនាស់ផលប្រយោជន៍របស់ក្រុមហ៊ុន MSC ដែលមានចែងនៅក្នុងកាតព្វកិច្ចរាយការណ៍សម្រាប់និយោជិកទាំងអស់។

យើងសូមស្នើរនិយោជិកទាំងអស់បើកចំហប្រាប់ព័ត៌មានអំពីទំនាស់ផលប្រយោជន៍ធំៗ ឬពិតប្រាកដណាមួយតាមរយៈការបំពេញ និងបញ្ជូនបញ្ជី/តារាងសំណួរអំពីទំនាស់ផលប្រយោជន៍ដោយយោងតាមសេចក្តីណែនាំដែលមានចែងនៅក្នុង គោលនយោបាយគ្រប់គ្រងទំនាស់ផលប្រយោជន៍របស់ក្រុមហ៊ុន MSC នេះ។ និយោជិកដែលគ្មានបញ្ហាទំនាស់ផលប្រយោជន៍ដែលត្រូវរាយការណ៍ នឹងនៅតែត្រូវបំពេញ និងបញ្ជូនបញ្ជី/តារាងសំណួរអំពីទំនាស់ផលប្រយោជន៍នេះដដែល។ ជាការបន្ថែម និយោជិកមានទំនួលខុសត្រូវលើការធ្វើបច្ចុប្បន្នភាពព័ត៌មានដែលបានបើកចំហប្រាប់ ដើម្បីធានាឲ្យបានថា ការបើកចំហបែបនេះមានលក្ខណៈត្រឹមត្រូវពិតប្រាកដគ្រប់ពេល។

នៅគ្រប់ពេលដែលបញ្ហាទំនាស់ផលប្រយោជន៍ប្រភេទមួយនេះកើតឡើង ឬសូម្បីតែករណីលេចឡើងទាក់ទងក្នុងបញ្ហានេះ និយោជិកប្រភេទនេះត្រូវទទួលបាននូវលិខិតអនុញ្ញាតជាក់លាក់សិន មុននឹងចូលរួមក្នុងការងារអាជីវកម្មដែលភាពមិនលំអៀងរបស់គាត់ទំនងជានឹងមានការចោទសួរ។ បើករណីទំនាស់ផលប្រយោជន៍ទាក់ទងនឹងតម្លៃជាទឹកប្រាក់ធំមួយនៃការងារអាជីវកម្មដើម្បីក្រុមហ៊ុន MSC វាត្រូវតែមានការជម្រះបញ្ជីដោយថ្នាក់គ្រប់គ្រងសំខាន់ជាប់ពាក់ព័ន្ធ នៅពេលមានការសង្ស័យរបស់គណៈគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន MSC។



# បទបញ្ញត្តិច្បាប់ស្តីពីការដាក់ទណ្ឌកម្ម

ការដាក់ទណ្ឌកម្មគឺជាការហាមឃាត់ប្រឆាំងនឹងប្រតិបត្តិការអន្តរជាតិដែលបានបញ្ជាក់ពាក់ព័ន្ធនឹងបុគ្គល, អង្គភាព, ទំនិញ, ប្រទេស ឬនាវា ដើម្បីសម្រេចឲ្យបាននូវទិសដៅការពារសន្តិសុខ/នយោបាយជាតិមួយ។

ការអនុវត្តន៍ ឬការអនុលោមតាមការដាក់ទណ្ឌកម្មរបស់ប្រទេសស្វីស និងសហភាពអឺរ៉ុប គឺស្ថិតនៅលើចំណុចសំខាន់នៃគំរូធ្វើពាណិជ្ជកម្ម/អាជីវកម្មរបស់ក្រុមហ៊ុន MSC។ អាស្រ័យហេតុនេះ អនុវត្តន៍ ដោយមិនគិតដល់ពាណិជ្ជកម្ម ឬមុខទំនិញដែលបានដឹកជញ្ជូនឡើយ។

MSC បានបង្កើត និងដំណើរការកម្មវិធី អនុវត្តន៍តាមបញ្ជាដាក់ទណ្ឌកម្មដែលរួមមានកម្រងទម្រង់ការ ឬនីតិវិធីដែលនឹងធានាបាននូវការអនុលោម ឬអនុវត្តន៍តាមច្បាប់ដាក់ទណ្ឌកម្មពាក់ព័ន្ធទាំងអស់ដែលផ្តោតជាសំខាន់មិនត្រឹមតែលើទំនិញប៉ុណ្ណោះទេ (រួមទាំងការកំណត់ផ្លូវ) និងភាគីនានានៃកិច្ចសន្យាដឹកជញ្ជូន តែក៏ផ្តោតផងដែរលើនាវានានា (រួមមានកម្មសិទ្ធិ និងការកំណត់ផ្លូវ) និងឈ្មោះក្រុមហ៊ុនផ្គង់ផ្គង់របស់ MSC ផងដែរ។ រហូតមកដល់ពេលនេះ កម្មវិធីបណ្តុះបណ្តាល និងកម្មវិធីឧបករណ៍ព័ត៌មានវិទ្យា (IT) សម្រាប់ផ្តល់ឲ្យបុគ្គលិកដាក់លាក់ មានការបង្កើតឡើងដើម្បីបណ្តុះបណ្តាលនិយោជិក និងដំណើរការកម្មវិធីអនុលោម ឬអនុវត្តន៍តាមច្បាប់ ដាក់ទណ្ឌកម្មរបស់ក្រុមហ៊ុន MSC រួចហើយ។

# ការលាងលុយកខ្វក់

ការលាងលុយកខ្វក់កើតមានឡើងនៅពេលដែលបុគ្គលម្នាក់ធ្វើនូវទង្វើមួយដែលមានគោលបំណងបង្កឧបសគ្គដល់ការកំណត់ប្រភេទនៃប្រភពដើម, ការរកប្រភព ឬការរឹបអូសយកទ្រព្យសម្បត្តិដែលខ្លួនដឹង ឬត្រូវតែទទួលកាន់កាប់ដែលបានពីបទឧក្រិដ្ឋមួយ។

ទីភ្នាក់ងារ និងនិយោជិកនានាមានការហាមប្រាមដាច់ខាតពីការចូលរួមនៅក្នុង ឬសម្របសម្រួលប្រតិបត្តិការលាងលុយកខ្វក់។

ទីភ្នាក់ងារ និងនិយោជិកនានាគ្រាន់តែត្រូវអនុវត្តន៍សកម្មភាពអាជីវកម្ម/ពាណិជ្ជកម្មស្របច្បាប់ប៉ុណ្ណោះ និងមិនត្រូវយល់ព្រមទទួលយក ឬកាន់កាប់សាច់ប្រាក់ ឬទ្រព្យសម្បត្តិផ្សេងៗទៀតដែលពួកគេមានមូលហេតុដែលសង្ស័យថាជាអ្វីៗដែលបានមកពីបទឧក្រិដ្ឋឡើយ។



# ច្បាប់ស្តីពីការប្រកួតប្រជែង

MSC មានគោលនយោបាយតឹងរឹងមួយអំពីការអនុលោម អនុវត្តន៍តាមបទបញ្ញត្តិច្បាប់ប្រកួតប្រជែងដែលពាក់ព័ន្ធ (ដែលលើសពីនេះ ត្រូវបានគេហៅថា៖ “ច្បាប់ស្តីពីការប្រកួតប្រជែង (Antitrust Laws)”) គ្រប់ពេល និងគ្រប់ទីកន្លែង។ និយោជិក និងទីភ្នាក់ងារទាំងអស់ត្រូវអនុវត្តន៍តាមសៀវភៅណែនាំអំពីអនុវត្តន៍ច្បាប់ប្រកួតតប្រជែងរបស់ក្រុមហ៊ុន MSC។

ការបំពានច្បាប់ប្រកួតប្រជែង មានការដាក់ពិន័យយ៉ាងតឹងរឹងដោយច្បាប់ដែលមានជាអាទិ៍ ការផ្តន្ទាទោសនៅតាមប្រទេស។

ទីភ្នាក់ងារ និងនិយោជិតដែលទទួលបានសំណើសុំព័ត៌មានពីអាជ្ញាធរសាធារណៈ ឬរដ្ឋមួយ (មានជាអាទិ៍ ការស៊ើបអង្កេត និងសវនកម្មរបស់រដ្ឋាភិបាល) ត្រូវតែផ្តល់ព័ត៌មានជាបន្ទាន់ដល់ក្រុមការងារគ្រប់គ្រងការប្រកួតប្រជែងស្របច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។

ក្នុងករណីមាន “ការឆ្មក់ចូលឆែកឆេរពេលព្រលឹមស្រាងៗដោយប៉ូលិស” ឬការត្រួតពិនិត្យមិនប្រកាសប្រាប់មុនដែលផ្តួចផ្តើមឡើងដោយអាជ្ញាធរគ្រប់គ្រងការប្រកួតប្រជែងមួយ ត្រូវមានការទាក់ទងជាបន្ទាន់មកកាន់ក្រុមការងារគ្រប់គ្រងការប្រកួតប្រជែងស្របច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ (ដើម្បីទទួលបានសេចក្តីណែនាំច្រើនទៀតអំពីប្រធានបទឬខ្លឹមសារនេះ សូមមេត្តាមើល “សេចក្តីណែនាំអំពីការឆ្មក់ចូលឆែកឆេរពេលព្រលឹមស្រាងៗដោយប៉ូលិស” ដែលអាចមាននៅប្រពន្ធ័Internetរបស់ក្រុមហ៊ុន MSC)។

ផ្នែកសំខាន់មួយនៃការប្រព្រឹត្តខុសច្បាប់ គឺការព្រមព្រៀងជាមួយក្រុមហ៊ុនផ្សេងៗទៀតដែលគោលបំណងរបស់ពួកគេ គឺដើម្បីបង្អាក់ដល់ការប្រកួតប្រជែង (“ការសមគំនិត (ការព្រមព្រៀងជាសម្ងាត់)”)។ ជាឧទាហរណ៍ បញ្ហាទាំងនេះរួមមាន ការសមគំនិត (ការព្រមព្រៀងជាសម្ងាត់) ជាមួយនឹងអ្នក/ក្រុមហ៊ុនប្រកួតប្រជែងដែលទាក់ទងនឹង:

- ការព្រមព្រៀងគ្នាទាក់ទងនឹងកត្តាណាមួយនៃតម្លៃ (ឧទាហរណ៍ អត្រាតម្លៃ, ការបញ្ចុះតម្លៃ, ថ្លៃបន្ថែម, រយៈពេលទូទាត់) ដែលគេស្គាល់ថាជា *“ការដាក់តម្លៃថេរ”*;
- ការព្រមព្រៀងគ្នាដែលប៉ះពាល់ដល់របៀបដែលភាគីទាំងពីរលាតត្រដាងសមត្ថភាពរបស់វា (រួមមានកិច្ចព្រមព្រៀងលើការធ្វើឲ្យដំណើរការកាន់តែមានប្រសិទ្ធភាពនៅក្នុងក្រុមហ៊ុន, កម្រិតខ្ពស់ជាងលើការប្រើប្រាស់, កិច្ចព្រមព្រៀងទុកឲ្យនាវាអសកម្ម) ដែលគេស្គាល់ថាជា *“ការដាក់កំហិតសមត្ថភាព”*;
- ការព្រមព្រៀងគ្នាដែលនឹងមិនបើកឲ្យមានការប្រកួតប្រជែងសេវាកម្ម ឬឲ្យដកការប្រកួតប្រជែងសេវាកម្ម, ឬការព្រមព្រៀងគ្នាដែលនឹងមិនទៅដល់អតិថិជននៃក្រុមហ៊ុនប្រកួតប្រជែងដែលគេស្គាល់ថាជា *“ការយល់ព្រមចែករំលែកទីផ្សារ”*។

ការផ្លាស់ប្តូរព័ត៌មានលើផ្នែកពាណិជ្ជកម្មជាមួយនឹងក្រុមហ៊ុនប្រកួតប្រជែង (ឧទាហរណ៍ តម្លៃ, ថ្លៃចំណាយ, ការចាប់ផ្តើមដំណើរការលក់ផលិតផល ឬផែនការពាណិជ្ជកម្ម, បរិមាណ) នូវទិន្នន័យភាគហ៊ុនលើទីផ្សារដែលមានលក្ខណៈខុសច្បាប់ និងមានការហាមឃាត់ដាច់ខាត។ ចូរកត់សំគាល់ថា សេចក្តីប្រកាសជាសាធារណៈអំពីតម្លៃនៃទំនិញ ឬហ៊ុនដែលជួញដូរបបច្ចុប្បន្នតែប្រគល់នៅពេលក្រោយកើនឡើង (“ការឲ្យសញ្ញា”) តាមរយៈWebsiteឬសេចក្តីប្រកាសព័ត៌មាន ក៏អាចនឹងមានការចាត់ទុកជាការប្រឆាំង ឬបង្អាក់ការប្រកួតប្រជែងបានដែរ។

ការរំលោភលើច្បាប់ការពារការប្រកួតប្រជែង ក៏អាចកើតចេញពីការបំពានលើស្ថានភាពមានប្រៀបមួយបានដែរ។ ស្ថានភាពមានប្រៀបមួយមានលក្ខណៈស្របច្បាប់ និងមាននៅកន្លែងដែលក្រុមហ៊ុនមួយមានវត្តមាននៅលើទីផ្សារកំពុងឡើងខ្ពស់បែបនេះដែលវាអាចប្រព្រឹត្តទៅដោយឯករាជ្យលើក្រុមហ៊ុនប្រកួតប្រជែង និងអតិថិជន។ ការបំពានលើស្ថានភាពមានប្រៀបមួយ មានលក្ខណៈខុសច្បាប់ និងកើតចេញពីការប្រើស្ថានភាពនេះដើម្បីធ្វើអាជីវកម្មលើអតិថិជន ឬផាត់ចេញនូវក្រុមហ៊ុនប្រកួតប្រជែង។ នៅលើទីផ្សារភាគច្រើនបំផុត ក្រុមហ៊ុន MSC ប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងគ្រប់គ្រាន់ដែលបញ្ហាទាំងនេះនឹងមិនកើតមានឡើងទេ តែការយកចិត្តទុកដាក់ត្រូវមានការធ្វើឡើងនៅលើទីផ្សារទាំងនោះដែលក្រុមហ៊ុន MSC កាន់កាប់ភាគហ៊ុនមានតម្លៃខ្ពស់នៅលើទីផ្សារ។ ឧទាហរណ៍ នៅក្នុងច្បាប់របស់សហភាពអឺរ៉ុប វាពិតជាមិនទំនងទាល់តែសោះថា ក្រុមហ៊ុនមួយនឹងត្រូវបានគេចាត់ទុកថាមានប្រៀបនោះទេ បើចំណែកភាគហ៊ុនលើទីផ្សាររបស់ខ្លួនដែលជួញដូរនោះមានទាបជាង 40%។

ចំណាំ: បើទោះបិជាវិធានច្បាប់ពិសេសអាចនឹងប្រើនៅក្នុងទំនាក់ទំនងទៅនឹងសមាគមក្រុមហ៊ុន ឬការប្រជុំមួយដែលមានជាអាទិ៍ ការព្រមព្រៀងពិភាក្សាគ្នាដោយស្ម័គ្រចិត្ត អ្នកក៏នៅតែត្រូវតែធានាឲ្យបាននូវការអនុលោម ឬអនុវត្តន៍តាមច្បាប់ការពារការប្រកួតប្រជែងដែរ។ ដើម្បីទទួលបានសេចក្តីណែនាំអំពីការដោះស្រាយបញ្ហានេះ សូមមេត្តាទាក់ទងក្រុមការងារគ្រប់គ្រងការប្រកួតប្រជែងស្របច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។



# កំណត់ត្រា អាជីវកម្ម និងហិរញ្ញវត្ថុ

ភាពត្រឹមត្រូវ និងការរក្សាបាននូវកំណត់ត្រាអាជីវកម្ម និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន MSC មានសារៈសំខាន់ណាស់ និងត្រូវតែមានការធានាឲ្យបាន។

ក្នុងការភ្ជាប់ទំនាក់ទំនងទៅនឹងចំណុចដែលបានលើកឡើងពីមុននេះ និយោជិកទាំងអស់ត្រូវតែ:

- ជានិច្ចកាល កត់ត្រា និងរៀបចំចំណាត់ថ្នាក់ប្រត្តិបត្តិការទៅក្នុងខួបគណនេយ្យឲ្យបានត្រឹម ត្រូវ និងនៅក្នុងគណនី និងផ្នែក ឬអង្គភាពពាក់ព័ន្ធពិតប្រាកដ
- មិនត្រូវធ្វើឲ្យខុសប្រភេទ (សភាពដើមពិត) នៃប្រតិបត្តិការណាមួយឡើយ
- មិនត្រូវក្លែង ឬបន្លំឯកសារណាមួយឡើយ
- មិនត្រូវបើកលទ្ធភាពឲ្យមនុស្សម្នាក់ទៀតប្រើងគេចពន្ធបាន, លាងលុយកខ្វក់, ឬរំលោភបំពានច្បាប់ផ្សេងៗឡើយ
- ជានិច្ចកាល ជួយគាំទ្រដល់ការប៉ាន់ប្រមាណ និងបំណុលទូទៅក្នុងគណនីដោយមានការបញ្ជាក់ឯកសារត្រឹមត្រូវ
- រក្សារកំណត់ត្រាសម្រាប់រយៈពេលជាមធ្យម 10 (ដប់) ឆ្នាំឡើងទៅ បើច្បាប់ក្នុងស្រុកបានកំណត់
- រក្សារឯកសារដែលបានស្នើសុំ និងមិនបោះចោល, ផ្លាស់ប្តូរ, លុបចោល, ឬបំផ្លាញចោលនូវព័ត៌មាន ឬឯកសារណាមួយដែលអាចនឹងសំខាន់ជាប់ទាក់ទងទៅនឹងការស៊ើបអង្កេត និង/ឬស្ថិតក្រោមលក្ខខណ្ឌពិសេសដើម្បីការពារទុកឯកសារពាក់ព័ន្ធបណ្តឹងផ្លូវច្បាប់។

# កិច្ចសន្យា

និយោជិកគ្រប់ៗរូបត្រូវតែទទួលបានការយល់ព្រមត្រឹមត្រូវទាំងអស់សិន មុននឹងប្រតិបត្តិ, កែសម្រួល, កែប្រែកិច្ចសន្យាណាមួយ។

សម្រាប់គោលបំណងនៃផ្នែកនេះ ពាក្យថាៈ “កិច្ចសន្យា” មានជាអាទិ៍ (តែមិនកំណត់ចំពោះ) កិច្ចសន្យាដឹកជញ្ជូន, កិច្ចសន្យាផ្តល់ស្ថានីយរបស់ក្រុមហ៊ុនគោលដៅ, កិច្ចព្រមព្រៀងប្រើនាវារួមគ្នា, កិច្ចព្រមព្រៀងដឹកញ្ជូនដោយភ្ជាប់ទំនាក់ទំនងគ្ គ្នា, កិច្ចព្រមព្រៀងរបស់ទីភ្នាក់ងារ, និងកិច្ចព្រមព្រៀងផ្គត់ផ្គង់ប្រេងឥន្ធនៈចាក់នាវា។ បើនិយោជិកមានសំណួរ ឬចម្ងល់ណាមួយ ឬចាំបាច់ត្រូវការដំបូន្មានអំពីបញ្ហាកិច្ចសន្យាណាមួយ ពួកគេត្រូវឆ្លើយឆ្លងគ្នាជាមួយនឹងការងារគ្រប់គ្រងកិច្ចសន្យាស្របច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។



# ព័ត៌មានសម្ងាត់, កិច្ចការពារទិន្នន័យ និងសិទ្ធិឯកជន, និងឧបករណ៍អេឡិចត្រូនិក

## ព័ត៌មានសម្ងាត់

និយោជិកត្រូវតែការពាររាល់ព័ត៌មានសម្ងាត់របស់ពួកគេដូចជាព័ត៌មានសម្ងាត់ណាមួយដែលទទួលបានពីអតិថិជនក្រុមហ៊ុនផ្គត់ផ្គង់របស់ក្រុមហ៊ុន MSC ឬទីភ្នាក់ងាររបស់ខ្លួន និងភាគីទីបីណាមួយផ្សេងទៀត។

ការខកខានធ្វើដូច្នោះនឹងនាំឲ្យមានការបំពានលើការបំពេញកាតព្វកិច្ចដែលមាននៅក្នុងកិច្ចសន្យាឬច្បាប់ត្រូវការពារការសម្ងាត់ក្នុងពាណិជ្ជកម្ម កិច្ចការពារទិន្នន័យ និងសិទ្ធិឯកជន។

ទោះស្ថិតក្នុងករណីណាក៏ដោយ ព័ត៌មានសម្ងាត់មិនត្រូវមានការបើកចំហប្រាប់ទៅមនុស្សណាម្នាក់ក្រៅក្រុមហ៊ុន MSC និងទីភ្នាក់ងាររបស់ខ្លួនជាដាច់ខាត (មានជាអាទិ៍ ក្រុមគ្រួសារ និងមិត្តភក្តិ លើកលែងករណីដែលមានតម្រូវផ្លូវការផ្លូវច្បាប់)។

មិនត្រូវមានការចែករំលែកព័ត៌មានសម្ងាត់ប្រាប់បន្តទៅអ្នកផ្សេងៗក្រៅពីក្រុមហ៊ុន MSC ឬទីភ្នាក់ងាររបស់លើកលែងដែល “ចាំបាច់ត្រូវការដឹង” ជាដាច់ខាត។ និយោជិកទាំងអស់មានកាតព្វកិច្ចការពារព័ត៌មានសម្ងាត់ សូម្បីក្រោយចាប់ការងារ ឬអាជីវកម្មក៏ដោយ។

## កិច្ចការពារទិន្នន័យ និងសិទ្ធិឯកជន

MSC គោរព និងការពារសិទ្ធិឯកជននៃនិយោជិក, អតិថិជន, និងដៃគូក្រុមហ៊ុនរបស់ខ្លួន ដោយដំណើរការប្រើទិន្នន័យផ្ទាល់ខ្លួនយោងតាមលក្ខខណ្ឌបង្កើតឲ្យមានឡើងដោយច្បាប់ និងបទបញ្ញត្តិច្បាប់ការពារទិន្នន័យដែលពាក់ព័ន្ធ។ វាធានាបានជាពិសេសនូវប្រសិទ្ធភាពនៃកិច្ចការពារទិន្នន័យរបស់បុគ្គល គេដំណើរការប្រើទិន្នន័យផ្ទាល់ខ្លួន។

ទិន្នន័យផ្ទាល់ខ្លួនត្រូវមានដំណើរការប្រើប្រាស់ឲ្យបានត្រឹមត្រូវ និងស្របច្បាប់ និងសម្រាប់គោលបំណងដែលបានបញ្ជាក់ និងត្រឹមត្រូវតាមច្បាប់។ រហូតមកដល់ពេលនេះ ក្រុមហ៊ុន MSC បានអនុម័តលើវិធានការការពារផ្នែកសន្តិសុខសុវត្ថិភាពផ្នែកបច្ចេកទេស និងអង្គភាពបានយ៉ាងត្រឹមត្រូវ ប្រយោជន៍ការពារទិន្នន័យផ្ទាល់ខ្លួនដែលខ្លួនដំណើរការប្រើ រក្សាទុក និងប្រកាន់យកការប្រុងប្រយ័ត្នខ្ពស់ដើម្បីទប់ស្កាត់ការបើកចំហដែលគ្មានការអនុញ្ញាតត្រឹមត្រូវ។

MSC លើកកម្ពស់ការយល់ដឹងជាទៀងទាត់ក្នុងចំណោមនិយោជិករបស់ខ្លួនលើបញ្ហាការពារទិន្នន័យ។

និយោជិកត្រូវយល់ដឹងកាតព្វកិច្ចរបស់ពួកគេដោយគោរពដល់ទិន្នន័យផ្ទាល់ខ្លួន និងភាពសម្ងាត់ និងត្រូវតែអនុលោម ឬអនុវត្តតាមកម្មវិធីអនុវត្តន៍តាមច្បាប់ការពារទិន្នន័យរបស់ក្រុមហ៊ុន MSC, ការណែនាំប្រាប់របស់ក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ និងមន្ត្រីការពារទិន្នន័យរបស់ក្រុមហ៊ុន MSC ដែលមានជាអាទិ៍ (តែមិនកំណត់ចំពោះ) ទំនាក់ទំនងទៅនឹងការប្រមូលការប្រើប្រាស់ និងការគ្រប់គ្រងទិន្នន័យផ្ទាល់ខ្លួន។ ទីភ្នាក់ងារ ឬនិយោជិកដែលកំពុងដឹងអំពីការបំពានវិធានច្បាប់ការពារទិន្នន័យ ត្រូវរាយការណ៍វាជាបន្ទាន់ប្រាប់ទៅក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។

## ឧបករណ៍អេឡិចត្រូនិក

ក្រុមហ៊ុន MSC និងទីភ្នាក់ងាររបស់ខ្លួនអាចនឹងផ្ដល់ឲ្យនិយោជិករបស់ខ្លួននូវឧបករណ៍អេឡិចត្រូនិកសម្រាប់គោលបំណងផ្ទាល់ខ្លួន។ និយោជិកគ្រាន់តែត្រូវប្រើប្រាស់ឧបករណ៍ប្រភេទអស់ទាំងនេះសម្រាប់គោលបំណងដែលខ្លួនចង់បាន និងត្រូវបង្អាក់ខ្លួនឯងពីការប្រើប្រាស់វាសម្រាប់គោលបំណងផ្ទាល់ខ្លួន។ ឧបករណ៍អេឡិចត្រូនិកត្រូវតែមានការប្រើប្រាស់ដោយយោងតាមគោលនយោបាយរបស់ក្រុមហ៊ុន MSC និងបណ្ដាទីភ្នាក់ងាររបស់ខ្លួន, និងតាមការណែនាំប្រាប់របស់ក្រុមការងារអនុវត្តន៍ច្បាប់របស់ក្រុមហ៊ុន MSC នៅហ្សឺណែវ។

ក្រុមហ៊ុន MSC ឬទីភ្នាក់ងាររបស់ខ្លួនមានសិទ្ធិត្រួតពិនិត្យតាមដានជានិច្ចលើកការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនានានៅក្នុងវិសាលភាពច្បាប់ដែលរួមមានទិន្នន័យ, ព័ត៌មាន, ព័ត៌មានសម្ងាត់ និងទិន្នន័យផ្ទាល់ខ្លួនណាមួយដែលបានរក្សាទុកនៅក្នុងឧបករណ៍ប្រភេទអស់នេះ។

# បណ្ដាញសង្គម និងការនិយាយជាសាធារណៈ

## ការប្រើប្រាស់បណ្ដាញសង្គមរបស់ក្រុមហ៊ុន

ក្រុមហ៊ុន MSC សូមលើកទឹកចិត្តឲ្យ និយោជិក ទាំងអស់ចូលរួមប្រកបដោយការទទួលខុសត្រូវ និងវិជ្ជាជីវៈនៅលើបណ្ដាញសង្គមរបស់ MSC ដែលជាមធ្យោបាយមួយនៃការបង្កើតចំណាប់អារម្មណ៍លើសេវាកម្មរបស់ MSC និងការបង្កើតឱកាសការងារក្រុមហ៊ុន។ MSC សូមលើកទឹកចិត្តឲ្យនិយោជិតប្រើប្រាស់ទំព័រផ្លូវការរបស់ MSC នៅលើបណ្ដាញសង្គម។ និយោជិតគ្រប់ៗរូបអាចចែករំលែក និងបញ្ចេញមតិយោបល់នៅលើខ្លឹមសារសរសេរប្រកាសណាមួយដែលមានការធ្វើឡើងនៅលើទំព័រផ្លូវការរបស់ MSC ដែលនៅលើបណ្ដាញសង្គម។

បើកាតព្វកិច្ចការងារនៃនិយោជិតណាម្នាក់ចាំបាច់ត្រូវការវាដើម្បីនិយាយក្នុងនាម MSC នៅក្នុងកម្មវិធីនៃបណ្ដាញសង្គម និយោជិតនោះត្រូវតែស្វះស្វែងរកការឯកភាពយល់ព្រមលើមាតិកាទំនាក់ទំនងបែបនេះពីផ្នែកទីផ្សារលើពិភពលោករបស់ក្រុមហ៊ុន MSC នៅហ្សឺណែវ (ដែលគេអាចទាក់ទងតាមអ៊ីម៉ែលដែលមានអាសយដ្ឋាន social@msc.com)។ ស្ថិតក្នុងករណីដែលនេះគឺដើម្បីឲ្យមានភាពញឹកញាប់ អាចនឹងមានការស្នើឲ្យ និយោជិកដែលបាននិយាយចូលរៀនក្នុងវគ្គហ្វឹកហ្វឺន ឬស្វែងយល់អំពីសេចក្តីណែនាំអំពីការប្រើប្រាស់បណ្ដាញសង្គមសម្រាប់ក្រុមហ៊ុន។ និយោជិក នោះដាច់ខាតមិនត្រូវឆ្លើយតបខ្លួនឯង ដោយគ្មានការឯកភាពយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើដូច្នោះជាមុនឡើយ។

នៅពេលកំពុងប្រើប្រាស់បណ្ដាញសង្គមសម្រាប់ក្រុមហ៊ុន MSC និយោជិក មិនត្រូវបិទប្រកាស ឬសរសេរបញ្ចេញទស្សនៈអំពីការបិទប្រកាសរបស់អ្នកផ្សេងទៀតដែលមានប្រភេទដូចជាដោយ “ការចុចចូលចិត្ត” លើការបិទប្រកាសមួយលើ Facebook, អ្វីមួយដែល MSC ឬដៃគូក្រុមហ៊ុន MSC នឹងរកឃើញថាមានចេតនារំលោភបំពានដែលមានជាអាទិ៍ បញ្ហាជាតិសាសន៍និយម, ពាក្យមួលបង្កាត់ជាតិសាសន៍, មតិយោបល់បែបប្រកាន់ភេទ, មតិយោបល់បែបរើសអើង, ពាក្យប្រមាថ, ភាសាឆ្គាំឆ្គង ឬអាសគ្រាម, ឬការថ្លែងដែលមិនពិតបែបព្យាបាទ ឬឥតតម្លៃ។

និយោជិក ដែលមានសំណួរ ឬចម្ងល់អំពីការទទួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងការប្រើប្រាស់បណ្ដាញសង្គម ត្រូវមើលគោលនយោបាយប្រើប្រាស់បណ្ដាញសង្គមដែលបានបោះពុម្ពផ្សាយនៅលើអ៊ីនត្រាណិតរបស់ក្រុមហ៊ុន MSC ឬទាក់ទងតាមអ៊ីម៉ែលដែលមានអាសយដ្ឋាន social@msc.com។

## ការនិយាយជាសាធារណៈ និងការចូលរួមក្នុងប្រព័ន្ធផ្សព្វផ្សាយ

MSC ទទួលស្គាល់ថា ជានិច្ចកាល និយោជិកអាចនឹងចង់ចូលរួមចំណែកក្នុងព្រឹត្តិការណ៍/កម្មវិធីនិយាយជាសាធារណៈ ឬការនិយាយទៅកាន់អ្នកសារព័ត៌មាន (អ្នកកាសែត) និងថាសកម្មភាពទាំងនេះអាចជួយកសាងទំនាក់ទំនងជាមួយបណ្ដាភាគីខាងក្រៅ និងផ្សព្វផ្សាយអំពីក្រុមហ៊ុន MSC និងសេវាកម្មរបស់ខ្លួន។ ការថ្លែងសន្ទរកថានៅក្នុងសន្និសីទ, ឬការធ្វើសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយមួយក៏ស្ថិតនៅក្នុងកម្រិត កម្រងជំនាញដែលនិយោជិកមួយចំនួនទទួលបានការលើកទឹកចិត្តឲ្យបង្កើតផងដែរ។

ការឡើងនិយាយនៅក្នុងព្រឹត្តិការណ៍/កម្មវិធីសាធារណៈមួយដែលនិយោជិកម្នាក់កំណត់អត្តសញ្ញាណបានជាក្រុមហ៊ុន MSC និងមតិយោបល់ណាមួយប្រាប់ដល់ប្រព័ន្ធផ្សព្វផ្សាយអាចមានការកំណត់អត្ថន័យថាជាការតំណាងមួយឲ្យក្រុមហ៊ុន MSC។ អាស្រ័យហេតុនេះ ក្រុមហ៊ុន MSC ចាំបាច់ត្រូវការធានាឲ្យបានថា មានការបើកចំហតែព័ត៌មានត្រឹមត្រូវសមស្របនៅក្នុងដែនសាធារណៈប៉ុណ្ណោះ និងថាការតំណាងឲ្យបែបអស់ទាំងនេះមានការធ្វើឡើងស្របតាមគោលនយោបាយរបស់ MSC, ចំពោះបទដ្ឋានមួយដែលផ្ដល់អត្ថប្រយោជន៍ដល់ម៉ាក្ស ឬយីហោនៃក្រុមហ៊ុន MSC និងក្នុងរបៀបដែលមានការសម្របសម្រួលមួយនៅទូទាំងក្រុមហ៊ុនជារួមរបស់យើង។

អាស្រ័យហេតុនេះ និយោជិកមានកាតព្វកិច្ចផ្ដល់ព័ត៌មានដល់ផ្នែកទំនាក់ទំនងសាធារណៈជារួមរបស់ MSC នៅហ្សឺណែវ & ផ្នែកទំនាក់ទំនងផ្ទៃក្នុងអំពីឱកាសនៃការនិយាយជាសាធារណៈ ឬការភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយសិន មុននឹងយល់ព្រមទទួលយកសំណើ។ សំណើទាំងនេះមានការពិនិត្យមើលឡើងវិញ និងការចុះសុពលភាពការសាកសួរ ឬការបដិសេធ/ច្រានចោល។ ក្នុងករណីមួយចំនួន ចាំបាច់ត្រូវមានការពិនិត្យលើការពិត ឬការបណ្ដុះបណ្ដាល និងការត្រៀមរៀបចំខ្លួន មុននឹងមានការបន្តផ្ដល់ភ្លើងបៃតង ឬការយល់ព្រម។

ដូចគ្នានឹងក្រុមហ៊ុនធំៗផ្សេងៗជាច្រើនទៀតដែរ ក្រុមហ៊ុន MSC ធ្វើប្រតិបត្តិការតាមរយៈអ្វីដែល MSC មានទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយតាមរយៈបុគ្គលដែលមានបទពិសោធន៍ក្នុងការយល់ដឹងលើចំណាប់អារម្មណ៍ និងតម្រូវការរបស់អ្នកសារព័ត៌មាន (អ្នកកាសែត)។ និយោជិកដែលមានទទួលបានការអនុញ្ញាតឲ្យចូលរួមពាក់ព័ន្ធដោយចៃដន្យពីសំណាក់អ្នកសារព័ត៌មាន ឬដែលគិតយ៉ាងសកម្មភាពជាមុនចំពោះការចូលរួមពាក់ព័ន្ធជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ អាចទាក់ទងផ្នែកទំនាក់ទំនងសាធារណៈជារួមរបស់ MSC នៅហ្សឺណែវ & ផ្នែកទំនាក់ទំនងផ្ទៃក្នុង ឬផ្ញើE-mailលមួយច្បាប់ទៅកាន់អាសយដ្ឋាន media@msc.comបាន។

និយោជិកនានាអាចមានសិទ្ធិមើលខ្លឹមសារគោលនយោបាយពេញលេញអំពីការការនិយាយជាសាធារណៈ និងចូលរួមពាក់ព័ន្ធជាមួយប្រព័ន្ធផ្សព្វផ្សាយប្រពន្ធ័Internetរបស់ក្រុមហ៊ុន MSC បាន។

MOVING THE WORLD, TOGETHER.

msc.com

© MSC Mediterranean Shipping Company SA, August 2021